# សៀវភៅណែនាំ

## សម្រាប់ភ្នាក់ងារអប់រំ (IPC)
## ផ្នែកទឹកស្អាត និងអនាម័យ
## នៅក្នុងខេត្តត្បូងឃ្មុំ



# មាតិកា


**សេចក្តីផ្តើម** ..... ២
មូលហេតុនៃការធ្វើអន្តរាគមន៍ផ្លាស់ប្តូរឥរិយាបថ ..... ២
គោលបំណងនៃសៀវភៅណែនាំ ..... ៤
អ្នកប្រើប្រាស់សៀវភៅណែនាំ ..... ៤
របៀប្រើប្រាស់សៀវភៅ ..... ៤
**ទិដ្ឋភាពទូទៅនៃអន្តរាគមន៍** ..... ៤
គោលគំនិតរួមនៃយុទ្ធនាការ ..... ៤
វិធីសាស្រ្តគន្លឹះ និងឧបករណ៍ ..... ៥
គោលបំណងនៃការផ្លាស់ប្តូរឥរិយាបថ ..... ៦

**ក្រុមគោលដៅ** ..... ៦

**ឧបករណ៍** ..... ៧

**សកម្មភាពរបស់ភ្នាក់ងារអប់រំ (IPC Agent)** ..... ១០

**សៀវភៅណែនាំពីវគ្គបណ្តុះបណ្តាល** ..... ១០
ការណែនាំលេខ១៖ផ្តល់វគ្គបណ្តុះបណ្តាលទៅមេភូមិ ..... ១០
ការណែនាំលេខ២៖ ភ្នាក់ងារអប់រំ IPC ទូរសព្ទ័តាមដានការទទួលសារសម្លេងតាមទូរស័ព្ទ ..... ១៨
ការណែនាំលេខ៣៖មេភូមិចុះពិនិត្យដល់ផ្ទះ ..... ៣០
ការណែនាំលេខ៤៖ វគ្គបណ្តុះបណ្តាលអ្នកលក់គ្រឿងប្លាស្ទិច និងសហគ្រាសតូច និងមធ្យមផ្នែកទឹកស្អាត និងអនាម័យ ..... ៣៤
ការណែនាំលេខ ៥៖ របៀបលក់ឧបករណ៍ទឹកស្អាត និងអនាម័យ ..... ៤៥

**ទំនាក់ទំនងព័ត៌មាន** ..... ៤៧

# សេចក្ដីផ្ដើម

## មូលហេតុនៃការធ្វើអន្តរាគមន៍ផ្លាស់ប្តូរឥរិយាបថ

គម្រោងលើកកម្ពស់ឥរិយាបថប្រកបដោយសុខុមាលភាព (PHB) គឺមានរយៈពេល៥ឆ្នាំដែលទទួលបានមូលនិធិពីទីភ្នាក់ងារសហរដ្ឋអាមេរិចសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ដែលដឹកនាំអនុវត្តដោយអង្គការអន្តរជាតិបំរើសុខភាពប្រជាជន (PSI)។ គម្រោង PHB គឺត្រូវបានអនុវត្តដោយមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយនឹងមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព(NCHP) និងក្នុងភាពជាដៃគូជាមួយក្រុមហ៊ុន17 Triggers។គម្រោង PHB គឺមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវឥរិយាបថសុខភាពក្នុងចំណោមប្រជាជនកម្ពុជា និងគាំទ្រនូវគោលដៅរបស់USAIDកម្ពុជា ដើម្បីធានាថាប្រជាជនកម្ពុជាស្វែងរកនិងទទួលបាននូវការថែទាំសុខភាពប្រកបដោយគុណភាពដោយកាត់បន្ថយនូវការចំណាយផ្សេងៗ តាមរយៈប្រព័ន្ធដែលមាននិរន្តរភាព។

បើតាមការស្ទង់មតិអំពីសុខភាព និងប្រជាសាស្ត្រថ្មីៗក្នុងឆ្នាំ២០១៤បានរកឃើញថា១៦% នៃគ្រួសារប្រើប្រាស់ទឹកពីប្រភពដែលបានកែលម្អក្នុងរដូវវស្សានិង ៣៥% នៅរដូវប្រាំង ។ហើយមានគ្រួសារប្រមាណតែ ៣១% ប៉ុណ្ណោះដែលបានប្រើប្រាស់វិធីសមស្របដើម្បីបរិសុទ្ធទឹក (ដាំទឹក ប្រើសារធាតុធ្វើឱ្យថ្លា និងចម្រោះជាដើម)។

ការសិក្សាដើមគ្រារបស់គម្រោង PHB នៅក្នុងខែកញ្ញា ឆ្នាំ២០១៩ដើម្បីបង្កើតសូចនាករដើមគ្រាសម្រាប់សកម្មភាពនៃផ្លាស់ប្តូរឥរិយាបថដើម្បីវាស់វែងលទ្ធផលនៅពាក់កណ្ដាល និងចុងគ្រាបានបង្ហាញថាការលាងសម្អាតដៃនឹងសាប៊ូគឺបានធ្វើឡើងភាគច្រើននៅពេលចេញពីបង្គន់៧១% ខណៈដែលអ្នកតបសម្ភាសន៍តែ២២,៧% ប៉ុណ្ណោះបានលើកថាបានលាងសម្អាតដៃនឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង៥ ដែលបានកំណត់ដោយ UNICEF។

កុមារអាយុក្រោម៥ឆ្នាំប្រមាណ ១៣% បានរកឃើញថារាកក្នុងរយៈ២សប្ដាហ៍ចុងក្រោយហើយ ១៥% នៃកុមារទាំងនោះប្រើប្រាស់ប្រភពទឹកដែលមិនទាន់បានកែលម្អក្នុងរយៈពេលនោះ។ នេះបញ្ជាក់ឱ្យឃើញថាប្រភពទឹកមិនមែនជាមូលហេតុតែមួយគត់ដែលធ្វើឱ្យរាកនោះទេចំណុចបង្កដទៃផ្សេងទៀតអាចត្រូវបានរកឃើញថាតាំងពីការយកទឹក និងការបរិភោគទឹក ឬអាហារ។ កុមារក្រោមអាយុ៥ឆ្នាំប្រមាណ ៣២% គឺមានបញ្ហាក្រេះក្រិន និង៩% ទៀត គឺស្ថិតក្នុងស្ថានភាពក្រេះក្រិនធ្ងន់ធ្ងរ។ ភាពក្រេះក្រិនគឺបណ្ដាលមកពីការរួមបញ្ចូលគ្នានៃកង្វះអាហាររូបត្ថម្ភ និងការឆ្លងរោគផ្ទួនៗ នៅវ័យកុមារតូចដែល ២៥% ដោយសារធ្លាប់មានបញ្ហារាកយ៉ាងហោចណាស់៥ដងនៅអាយុក្រោម២ឆ្នាំ និង ១៨% ធ្លាប់រាកយ៉ាងហោច ២ដងនៅអាយុក្រោម ២ឆ្នាំ។ ដោយមើលឃើញថាបញ្ហារាក និងអនាម័យគឺមានទំនាក់ទំនងយ៉ាងខ្លាំង ដូច្នេះការធ្វើឱ្យប្រសើរឡើងផ្នែកអនាម័យ នឹងជួយកាត់បន្ថយបញ្ហាក្រេះក្រិន។ គម្រោងP H B បានរៀបចំសិក្ខាមួយថ្ងៃ ដើម្បីធ្វើការសម្រេចរួមគ្នាលើបញ្ហាសុខភាពអាទិភាព និង ឥរិយាបថសុខភាពដែលត្រូវដោះស្រាយកាលពី ខែកុម្ភៈ ឆ្នាំ២០២០នៅសណ្ឋាគារហេង សុខាខេត្តត្បូងឃ្មុំដែលមានអ្នកចូលរួមចំនួន២៣រូប (មិនរាប់បញ្ចូលក្រុមការងារ PHB)។ ទឹកស្អាត និងអនាម័យត្រូវបានកំណត់ជាច្រកចូលសំខាន់ត្រូវដោះស្រាយ ដើម្បីសម្រេចបាននូវគោលបំណងខាងលើ។ទឹកស្អាត និងអនាម័យ WASH គឺត្រូវបានបោះឆ្នោតជាបញ្ហាសុខភាពអាទិភាពដែលត្រូវដោះស្រាយដំបូងគេក្នុង ខេត្តត្បូងឃ្មុំ ក្នុងនោះផងដែរឥរិយាបថសុខភាពផ្នែកទឹកស្អាតនិងអនាម័យចំនួន២ត្រូវបានសម្រេចនិងត្រូវផ្ដោតយកចិត្តទុកដាក់ដោះស្រាយមានដូចជា៖

### ១. ការលាងសម្អាតដៃនឹងសាប៊ូ

- មុនពេលធ្វើម្ហូប ឬប៉ះគ្រឿងម្ហូបអាហារ
- មុនពេលបរិភោគ
- មុនពេលបញ្ចុកក្មេង
- បន្ទាប់ពីលាងសម្អាតគូទទារក
- បន្ទាប់ពីបន្ទោបង់

### ២. ដាំ ឬចម្រោះទឹក និងរក្សាទុកឱ្យមានសុវត្ថិភាព

គម្រោងPHB បានកំណត់យកកញ្ចប់ឧបករណ៍ *យាយគំរូ* (បានបង្កើតឡើងដោយ iDE ក្នុងភាពជាដៃគូជាមួយក្រសួងអភិវឌ្ឍន៍ជនបទ (MRD) និងធនាគារពិភពលោក (WB) ដែលជាអន្តរាគមន៍មួយដែលមានសក្ដានុពលដែលគម្រោង PHB អាចរៀនតាមបានលឿនពីអន្តរាគមន៍ដែលមានស្រាប់ផ្នែកផ្លាស់ប្តូរឥរិយាបថសង្គម ដ៏មានប្រសិទ្ធភាពមួយនេះ។ PHB បានសម្រេចដាក់បន្ថែមនូវសកម្មភាពផ្លាស់ឥរិយាបថដោយផ្អែកលើទ្រឹស្តី Nudge ឬរំលឹកសម្រាប់សកម្មភាពនៃការផ្លាស់ប្ដូរឥរិយាបថផ្នែកទឹកស្អាត និងអនាម័យនេះ។ តាមរយៈលទ្ធផលពីការសិក្សាស្រាវជ្រាវ និងវិភាគលើឥរិយាបថក្រុមគោលដៅ និងសិក្ខាសាលាស្វែង រកដំណោះស្រាយជាមួយដៃគូស្នូល និងអ្នកពាក់ព័ន្ធលើការងារទឹកស្អាត និងអនាម័យក្រុមការងារបានទូរស័ព្ទចាប់ផ្ដើមរៀបចំអន្តរាគមន៍ទឹកស្អាតនិងអនាម័យដោយផ្អែកលើទ្រឹស្តី Nudge ដែលបំពេញបន្ថែមលើយុទ្ធសាស្ត្រអន្តរាគមន៍ *យាយគំរូ* របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

គោលបំណងនៃសកម្មភាពផ្លាស់ប្តូរឥរិយាបថ WASH គឺដើម្បីបង្កើតសកម្មភាពនៃការលាងសម្អាតដៃ នឹងសាប៊ូឱ្យបានញឹកញាប់នៅពេលវេលាសំខាន់ៗ ទាំង៥និងបង្កើនការហូបទឹក ដែលបានដាំឬចម្រោះ និងរក្សាទុកឱ្យមានសុវត្ថិភាព។ ការបង្កើតអន្តរាគមន៍នេះឡើង គឺមានគោលដៅសម្រេចឱ្យបាននូវគោលបំណង នៃសកម្មភាពផ្លាស់ប្តូរឥរិយាបថសង្គម ដោយការរួមបញ្ចូលគ្នានូវការផ្តល់ចំណេះដឹងដែលរៀបចំតាមរយៈផ្ទាំងរូបភាព ធំ(Poster) ខិត្តប័ណ្ណឧករណ៍បំពងសម្លេងសារសម្លេងតាមទូរស័ព្ទការតាំងបង្ហាញនិងអនុសាសន៍ស្តីពីឧបករណ៍ទឹកស្អាតនិងអនាម័យ និងលើកទឹកចិត្តឱ្យក្រុមគោលដៅធ្វើកាតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យដោយខ្លួនឯងឬទិញពីអ្នកលក់គ្រឿងប្លាស្ទិចដែលនៅជិតបំផុតប្រសិនបើពួកគេមិនមានឧបករណ៍/សម្ភារ ឬចង់បានឧបករណ៍ដែលតម្លើងស្រេច។ ពួកគេអាចទាក់ទងមេភូមិសម្រាប់ព័ត៌មានបន្ថែម។ វិធីសាស្ត្រនេះគឺស្របនឹងទ្រឹស្តីវិទ្យាសាស្ត្រផ្នែកផ្លាស់ប្តូរឥរិយាបថ និងអនុសាសន៍ នៃការអនុវត្តជោគជ័យល្អៗលើពិភពលោកដោយការដាក់បញ្ចូលគ្នានូវផ្នែកអប់រំចំណេះដឹង និងការរចនាអ្វីមួយដើម្បីរំលឹកលើការអនុវត្តដើម្បីជំរុញឱ្យការផ្លាស់ប្តូរឥរិយាបថកាន់តែជោគជ័យ។ ចុងបញ្ចប់នៃការអនុវត្តអន្តរាគមន៍ និងការវិភាគគម្រោងនឹងពិនិត្យឡើងវិញលើករណីរៀនសូត្រ និងធ្វើបទបង្ហាញនូវអនុសាសន៍នានាដើម្បីធ្វើការកែសម្រួល និងចម្លងយកទៅអនុវត្តបន្តនៅខេត្តគោលដៅផ្សេងទៀតនៃគម្រោង។

## គោលបំណងនៃសៀវភៅណែនាំ

សៀវភៅណែនាំនេះ គឺណែនាំអំពីការបង្កើតអន្តរាគមន៍ និងណែនាំដល់ភ្នាក់ងារអប់រំ (IPC) អំពីតួនាទីរបស់ពួកគេក្នុងការអនុវត្ត។

- ផ្តល់នូវការណែនាំអំពីការបង្កើតអន្តរាគមន៍ និងតួនាទីភ្នាក់ងារអប់រំក្នុងការអនុវត្តការងារ
- បង្ហាញពីទិដ្ឋភាពទូទៅនៃអន្តរាគមន៍ និងគោលបំណងការផ្លាស់ប្តូរឥរិយាបថក្នុងវគ្គនីមួយៗ
- ផ្តល់ការយល់ដឹងពន្យល់ណែនាំជាជំហានក្នុងការសម្របសម្រួលវគ្គនីមួយៗ និងការប្រើប្រាស់ឧបករណ៍ទាំងឡាយដែលមានក្នុងអន្តរាគមន៍ផ្លាស់ប្តូរឥរិយាបថការងារទឹកស្អាត និងអនាម័យ

## អ្នកប្រើប្រាស់សៀវភៅណែនាំ

- ភ្នាក់ងារអប់រំសុខភាព (IPC Agent)

### របៀបប្រើប្រាស់សៀវភៅ

សៀវភៅណែនាំនេះអាចប្រើជាឧបករណ៍វគ្គបណ្តុះបណ្តាលរបស់ភ្នាក់ងារអប់រំ ឬជាសៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាលមេភូមិ និងអ្នកលក់គ្រឿងប្លាស្ទិច និងការតាមដានការងារផងដែរ។ ទោះជាយ៉ាងណាក៏ដោយវាមិនមានន័យថាជាសៀវភៅសម្រាប់អាននៅមុខអ្នកចូលរួមទេ។ សូមអានឱ្យយល់ពីខ្លឹមសារជំហាន និងការប្រើប្រាស់ឧបករណ៍នានានៃវគ្គនីមួយៗហើយសូមប្រើប្រាស់សៀវភៅនៅពេលដែលត្រូវការវា។

## ទិដ្ឋភាពទូទៅនៃអន្តរាគមន៍

### គោលគំនិតរួមនៃយុទ្ធនាការ

គោលគំនិតរួម នៃសកម្មភាពផ្លាស់ប្តូរ ឥរិយាបថនេះគឺ« មើលឃើញស្អាតមិន ប្រាកដថាមានសុវត្ថិភាពទេ »។ វត្តមាននៃភាពកខ្វក់ គឺជាហេតុផលគន្លឹះមួយដែលត្រូវបានពិពណ៌នាក្នុងពេលចុះសិក្សាផ្ទាល់ក្នុងមូលដ្ឋាជាមួយប្រជាពលរដ្ឋដែលប្រព្រឹត្តឥរិយាបថនេះជាឧទាហរណ៍ គឺដៃមើលទៅឃើញប្រឡាក់ ឬកខ្វក់ គឺជាហេតុផលគន្លឹះ ដែលជំរុញឱ្យលាងសម្អាតដៃនឹងសាប៊ូ។ ប្រជាពលរដ្ឋបានលើកឡើងយ៉ាងច្បាស់ថាដៃមើលទៅមិនឃើញប្រឡាក់ឬកខ្វក់ទេ គឺ មានន័យថាពួកគាត់ជឿជាក់ថាដៃពួកគាត់ស្អាត។ គំនិតដែលបង្កើតឡើងនេះគឺដើម្បីឆ្លើយតប នឹងសំណួរដែលប្រជាពលរដ្ឋជឿថាភាពកខ្វក់ និងមេរោគអាចមើលនឹងភ្នែកបាន។យើងចង់ ធ្វើការបញ្ជាក់ទៅកាន់ប្រជាពលរដ្ឋទូទៅថាមិនមែនមេរោគទាំងអស់អាចមើលឃើញទេ។ តាមរយៈសាររំលេចធំៗ និងសកម្មភាពត្រូវធ្វើច្បាស់ៗ៖លាងសម្អាតដៃរបស់អ្នក នឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង៥ និងដាំឬចម្រោះទឹកហូប និងរក្សាទុកហូបឱ្យមានសុវត្ថិភាពហើយលើកទឹកចិត្តពួកគាត់ឱ្យអនុវត្តនូវឥរិយាបថទាំងនេះដើម្បីការពារខ្លួនគាត់ និង គ្រួសារពួកគាត់។ ឧបករណ៍ទឹកស្អាតនិង អនាម័យ និងស្ទិកគ័ររំលឹកទាំងអស់នឹង ជួយរំលឹកក្នុងការប្រតិបត្តិនូវឥរិយាបថអនាម័យទាំងនោះ។

### វិធីសាស្រ្តគន្លឹះ និងឧបករណ៍

ដោយមានការប្រឹក្សាយោបល់ជាមួយអង្គការខេមរា ដែលជាអ្នកអនុវត្តសកម្មភាពនៅក្នុងខេត្តត្បូងឃ្មុំ នៃគម្រោង PHB គឺក្រុមការងារបានធ្វើការគូសវាសគំនិតពីការដំណើរការ នៃការ ចូលរួមរបស់ក្រុមគោលដៅផ្តល់ការ យល់ដឹងដល់ពួកគេស្តីពីទឹកស្អាតនិងអនាម័យដើម្បីអនុវត្តឥរិយាបថដែលចង់បានហើយរៀនសូត្រពីឧបករណ៍ដឹងស្អាត និងពីទីកន្លែងដែលត្រូវទិញឧបករណ៍ និងចេះពីរបៀបតម្លើង ព្រមទាំងការប្រើប្រាស់ឧបករណ៍ផងដែរ។

### លំហូរអន្តរាគមន៍/ឧបកណ៍ ក្នុងស្ថានភាពកូវីត-១៩

ឧបករណ៍មានស្រាប់ អាចយកទៅអនុវត្តតាមផែនការដែលមានស្រាប់។

ឧបករណ៍ថ្មី: គឺត្រូវបានស្នើឡើងដើម្បីអនុវត្តសកម្មភាពផ្នែកទឹកស្អាត និងអនាម័យក្នុងស្ថានភាពបច្ចុប្បន្ន និងការរឹតបន្តឹងនៃបញ្ហាកូវីត។



<table>
<tr><th>ការយល់ដឹង</th><th>ការពិចារណា</th><th>ការចូលរួម</th><th>ការផ្លាស់ប្តូរ</th><th>បន្ទាប់ពីលក់</th></tr>
<tr><td>ចាក់ឧបករណ៍បំពងសម្លេងនៅផ្ទះមេភូមិ</td><td rowspan="3">សារទូរស័ព្ទ Robocalls</td><td rowspan="2">តម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យនៅផ្ទះមេភូមិ</td><td rowspan="4">ទិញ/បង្កើត Wash Kit</td><td>អតិថិជនទូរស័ព្ទទៅមេភូមិដើម្បីបានសាប៊ូឥតគិតថ្លៃ</td></tr>
<tr><td>ចាក់ឧបករណ៍បំពងសម្លេងនៅតូបលក់ឧបករណ៍ទឹកស្អាតនិងអនាម័យ</td><td rowspan="2">មេភូមិចុះដល់ផ្ទះមើលការតម្លើងឧបករណ៍ប្រគល់សាប៊ូនិងកត់ត្រាព័ត៌មាន</td></tr>
<tr><td>បិទposterក្នុងភូមិ មណ្ឌលសុខភាព និងផ្សារ</td><td rowspan="2">IPC ទូរស័ព្ទតាមដានពីការទទួលសារ+វាយតម្លៃដើមគ្រា</td></tr>
<tr><td colspan="2">ខិត្តប័ណ្ណផ្សព្វផ្សាយចែកដោយមេភូមិ/អាចរកបាននៅផ្ទះមេភូមិ (ការចុះជួបផ្ទាល់តាមផ្ទះជាឱកាសដែលយកលេខទូរស័ព្ទផ្ទះគោលដៅ)</td><td>MELរៀបចំការវាយតម្លៃចុងគ្រា</td></tr>
</table>

### គោលបំណងនៃការផ្លាស់ប្តូរឥរិយាបថ

យើងចង់ឱ្យអ្នកសម្រេចចិត្តក្នុងគ្រួសារ ទាំងឡាយដែលមាន ចំណូលទាបនៅជនបទខេត្តត្បូងឃ្មុំតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យនៅផ្ទះ និងលើកទឹកចិត្តឱ្យសមាជិកគ្រួសារប្រើវាដូច្នេះគ្រួសាររបស់ពួកគាត់អាចលាងសម្អាតដៃ នឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង ៥និងដាំឬចម្រោះទឹកហូប និងរក្សាទុកឱ្យមានសុវត្ថិភាព។

## ក្រុមគោលដៅ

អន្តរាគមន៍នេះនឹងត្រូវការ ការចូលរួមពីប្តី និងប្រពន្ធដើម្បីដោះស្រាយនូវឧបសគ្គទាំងឡាយដែលពួកគេនិងគ្រួសារជួបប្រទះ

| ឥរិយាបថក្រុមគោលដៅ | បរិយាយ |
|---|---|
| **ឥរិយាបថបច្ចុប្បន្ន** | • លាងសម្អាតដៃនឹងសាប៊ូពេលឃើញដៃប្រឡាក់<br>• លាងសម្អាតដៃនឹងទឹក (ហើយអាចលាងនឹងសាប៊ូ) មុនពេលបរិភោគហើយសម្រាប់បងប្អូនឥស្លាម គឺមុនពេលថ្វាយបង្គំ<br>• លាងសម្អាតដៃជាមួយទឹក (ភាគច្រើន) នឹងសាប៊ូពេលបត់ជើងធំរួច<br>• ដាំទឹកសម្រាប់ហូប<br>• ទុកទឹកក្នុងកំសៀវ ឬឆ្នាំង<br>• ចាក់ទឹកដែលដាំរួចចូលក្នុងដបទឹកដែលចាស់កខ្វក់ ហើយដាក់ក្លាសេក្នុងធុងទឹកកកឬយកទៅស្រែ |

| | |
|---|---|
| **ឧបសគ្គក្នុងការទទួលយកនូវឥរិយាបថដែលណែនាំ** | • ពួកគេមិនដឹងថាចាំបាច់ត្រូវលាងសម្អាតដៃ ពេលពួកគេមើលដៃមិនឃើញប្រឡាក់<br>• ពួកគេមិនមានលទ្ធភាពទិញឧបករណ៍ទឹកស្អាត និងអនាម័យ<br>• ពួកគេមិនចង់ចំណាយប្រាក់ទិញឧបករណ៍ឧករណ៍ទឹកស្អាត និងអនាម័យនៅពេលដែលពួកមានទឹកនិងសាប៊ូសម្រាប់ប្រើប្រាស់<br>• ពួកគេមិនធ្លាប់រាកឬមានជំងឺដែលបណ្តាលមកពីការខ្វះអនាម័យដូច្នេះហើយពួកគេមិនគិតថាត្រូវផ្លាស់ប្តូរទម្លាប់ដែលពួកគេកំពុងអនុវត្តនោះទេ |
| **កត្តាជំរុញក្នុងការទទួលយកឥរិយាបថដែលណែនាំ** | • ដឹងពីប្រសិទ្ធភាពនៃសាប៊ូ ដែលអាចកំចាត់មេរោគបាន<br>• អ្នកមើលថៃក្មេង(ជាពិសេស)គឺជាគោលដៅដែលត្រូវបានលើកទឹកចិត្តដើម្បីឱ្យគ្រួសារជាពិសេសសកូនៗរបស់ពួកគេមានសុខភាពល្អនិងសុវត្ថិភាពដូច្នេះកូនៗអាចទៅសាលារៀន ហើយការសិក្សាកាន់តែប្រសើរ។<br>• កន្លែងលាងសម្អាតដៃ និងដបទឹកគឺជាគោលដៅដែលត្រូវយកចិត្តទុកដាក់ និងធ្វើឱ្យទំនើប។<br>• កន្លែងលាងសម្អាតដៃគឺមានភាពងាយស្រួល និងកាន់តែរីករាយសម្រាប់សមាជិកគ្រួសារក្នុងការប្រើប្រាស់។<br>• ការផ្តល់សាប៊ូដោយឥតគិតថ្លៃ គឺជាគោលដៅសំខាន់បំផុត<br>• ស្ទិកគ័ររំលឹកគឺមានភាពទាក់ទាញ និងជាគោលដៅសំខាន់។<br>• ពួកគេជឿជាក់លើការណែនាំរបស់មេភូមិ ។<br>• ពួកគេឃើញមណ្ឌលសុខភាពចែករំលែកព័ត៌មានដូចគ្នាដែរ។ |

## ឧបករណ៍

| ឧបករណ៍ | គោលបំណងនៃឥរិយាបថ | សារគន្លឹះ | សកម្មភាពអនុវត្ត |
|---|---|---|---|
| | | **ឧបករណ៍ទឹកស្អាត និងអនាម័យ/តាមផ្ទះ** | |
| **ស្ទិកគ័រ** | ដើម្បីរំលឹកប្រជាជនធ្វើនូវឥរិយាបថដែលបានណែនាំ(លាងសម្អាតដៃនឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង៥និងហូបទឹកដែលបានដាំឬចម្រោះនិងរក្សាទុកឱ្យមានសុវត្ថិភាពប៉ុណ្ណោះ)<br> | កញ្ចប់ឧបករណ៍ទឹកស្អាតនិងអនាម័យមានស្ទិកគ័ររំលឹកចំនួន៥ផ្សេងៗគ្នា៖<br>១. មើលឃើញស្អាតមិនប្រាកដថាមានសុវត្ថិភាពទេ-លាងសម្អាតដៃនឹងសាប៊ូមុនពេលធ្វើម្ហូបបញ្ចុកក្មេងបរិភោគទៅកន្លែងលាងសម្អាតដៃនៅផ្ទះបាយ/កន្លែងហូបអាហារ<br>២. មើលឃើញស្អាតមិនប្រាកដថាមានសុវត្ថិភាពទេ -លាងសម្អាតដៃនឹងសាប៊ូក្រោយពេលលាងសម្អាតគូទទារកនិងបន្ទោបង់ទៅកន្លែងលាងសម្អាតដៃនៅបង្គន់ | - លាងសម្អាតដៃរបស់អ្នកនឹងសាប៊ូពេលវេលាសំខាន់ៗទាំង៥ |



| | | | |
|---|---|---|---|
| | <br> | ៣. មើលឃើញស្អាតមិនប្រាកដថាមានសុវត្ថិភាពទេx២ -ស្ទិកគ័រក្រាហ្វិកពីដំណើរការនៃការដាំឬចម្រោះនិងរក្សាទុក«ទឹកហូប» សម្រាប់បិទនៅលើធុងទឹក | ហូបតែទឹកដែលដាំឬចម្រោះនិងរក្សាឱ្យមានសុវត្ថិភាពតែប៉ុណ្ណោះ |
| **ស្ទិកគ័រអំពីទឹក** | សម្រាប់បិទនៅកន្លែងស្តុកទឹក/ទុយោទឹកដើម្បីរំលឹកប្រជាពលរដ្ឋថាទឹកនេះមិនមែនសម្រាប់ហូបទេ<br> | • ទឹកនេះមិនមែនសម្រាប់ហូបទេ | **កុំហូបទឹកនេះ** |

## ឧបករណ៍សម្រាប់ការចូលរួមសហគមន៍និងទីផ្សារ

| | | | |
|---|---|---|---|
| **ខិត្តប័ណ្ណ** | ដើម្បីផ្តល់ព័តមានបន្ថែមទាក់ទងនឹងឥរិយាបថផ្នែកទឹកស្អាតនិងអនាម័យដែលបានណែនាំរបៀបនៃការការពារពីមេរោគនិងការណែនាំពីរបៀបតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យ | សារសំខាន់ដែលដាក់បញ្ចូលក្នុងខិត្តប័ណ្ណមានដូចជា៖<br>- មើលឃើញស្អាតមិនប្រាកដថាមានសុវត្ថិភាពទេ<br>-របៀបការពារខ្លួននរណាម្នាក់និងគ្រួសារពីមេរោគ<br>- ការណែនាំពីឧបករណ៍ទឹកស្អាតនិងអនាម័យ<br>- ការណែនាំពីរបៀបតម្លើងឧបករណ៍លាងសម្អាតដៃដោយខ្លួនឯង<br>- ទំនាក់ទំនងព័ត៌មានទៅកាន់អ្នកផ្គត់ផ្គង់ឧបករណ៍ទឹកស្អាតនិងអនាម័យដែលនៅជិតបំផុត | ទិញឧបករណ៍ទឹកស្អាតនិងអនាម័យពីអ្នកលក់ដែលនៅជិតបំផុត<br><br>តម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យ |

| | | | |
|---|---|---|---|
| |  | -ទទួលបានសាប៊ូដោយឥតគិតថ្លៃសម្រាប់ការតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យនៅផ្ទះ។ | ទាក់ទងទៅមេភូមិដើម្បីចុះពិនិត្យដល់ផ្ទះនិងទទួលបានសាប៊ូឥតគិតថ្លៃ |

## ឧបករណ៍សម្រាប់ការទាក់ទង និងផ្តល់ព័ត៌មាន

| | | | |
|---|---|---|---|
| **ស្លាកសញ្ញា** | ដើម្បីផ្តល់ព័តមានប្រជាពលរដ្ឋថាឧបករណ៍ទឹកស្អាតនិងអនាម័យមានលក់នៅទីនេះ   | យើង(អ្នកលក់គ្រឿងប្លាស្ទិចនិងសហគ្រាសលក់ឧបករណ៍ទឹកស្អាតនិងអនាម័យ)គឺជាអ្នកលក់ឆ្នើមនិងមានឧបករណ៍ទឹកស្អាតនិងអនាម័យដែលអ្នកត្រូវការ | ទិញឧបករណ៍ទឹកស្អាតនិងអនាម័យនៅទីនេះ |
| **ផ្ទាំងរូបភាព** (Poster) | ដើម្បីផ្តល់ព័តមានស្តីពីទឹកស្អាតនិងអនាម័យនិងលើកទឹកចិត្តឱ្យតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យ   | ● មើលឃើញស្អាតមិនប្រាកដថាមានសុវត្ថិភាពទេសូមលាងសម្អាតដៃរបស់អ្នកនឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង៥និងហូបតែទឹកដែលបានដាំឬចម្រោះនិងរក្សាទុកឱ្យមានសុវត្ថិភាពប៉ុណ្ណោះ | តម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យដោយខ្លួនឯងទាក់ទងអ្នកលក់គ្រឿងប្លាស្ទិចដែលនៅជិតបំផុតទំនាក់ទំនងមេភូមិសម្រាប់ព័ត៌មានបន្ថែម |



## សកម្មភាពរបស់ភ្នាក់ងារអប់រំ (IPC Agent)

អន្តរាគមន៍នេះ គឺភ្នាក់ងារអប់រំដើរតួនាទីសំខាន់ដែលមានសកម្មភាពផ្សេងៗគ្នាដូចខាងក្រោម៖

១. បណ្តុះបណ្តាលមេភូមិ

២. ផ្តល់ឧបករណ៍ទឹកស្អាតនិងអនាម័យទៅមេភូមិដើម្បីតម្លើងនិងដាក់តាំងបង្ហាញ ព្រមទាំងជូនសាប៊ូមេភូមិ ដើម្បីស្តុកនិងជូនគ្រួសារ ដែលបានតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យបានត្រឹមត្រូវ

៣. បិទរូបភាពផ្ទាំងធំ (Poster) នៅទីប្រជុំជនក្នុងភូមិនិងមណ្ឌលសុខភាព

៤. បណ្តុះបណ្តាលអាជីវករលក់គ្រឿងប្លាស្ទិចនិងសហគ្រាសធុនតូចនិងមធ្យមផ្នែកទឹកស្អាតនិងអនាម័យ

៥. ជូនស្ទិកគ័រនិងខិត្តប័ណ្ណទៅអ្នកលក់ដើម្បីទុកចែកជូនគ្រួសារដែលបានទិញឧបករណ៍ទឹកស្អាតនិងអនាម័យ

៦. ផ្ញើសារសម្លេងតាមទូរស័ព្ទទៅកាន់គ្រួសារមិនទាន់មានឧបករណ៍ទឹកស្អាតនិងអនាម័យដែលបានជ្រើសរើស

៧. ទូរស័ព្ទតាមដានអ្នកដែលបានទទួលសារសម្លេងទូរស័ព្ទ (ដែលបានស្តាប់លើសពី៦៦%)

៨. តាមដានជាមួយអ្នកលក់និងកត់ត្រាចំនួនឧបករណ៍ទឹកស្អាតនិងអនាម័យដែលបានលក់

៩. តាមដានជាមួយមេភូមិដើម្បីរៀបចំការចុះពិនិត្យដល់ផ្ទះនិងការប្រមូលព័ត៌មាន

## សៀវភៅណែនាំពីវគ្គបណ្តុះបណ្តាល

**ការណែនាំលេខ ១៖ ផ្តល់វគ្គបណ្តុះបណ្តាលមេភូមិ**

| រយៈពេល | ក្រុមគោលដៅ | គោលបំណង |
|---|---|---|
| ១២០នាទី | - អ្នកចូលរួម៖ មេភូមិ<br>- អ្នកសម្របសម្រួល៖ ភ្នាក់ងារអប់រំIPC នៃអង្គការខេមរា | » មេភូមិយល់ពីបរិបទនៃគម្រោង PHB និងយុទ្ធសាស្ត្រ និងសកម្មភាពផ្លាស់ប្តូរឥរិយាបថផ្នែកទឹកស្អាតនិងអនាម័យ<br>» មេភូមិយល់ច្បាស់ពីតួនាទីនិងការទទួលខុសត្រូវនៃសកម្មភាពការផ្លាស់ប្តូរឥរិយាបថផ្នែកទឹកស្អាតនិងអនាម័យ ជាពិសេសការផ្តល់សារអប់រំផ្នែកទឹកស្អាតនិងអនាម័យនៅក្នុងមូលដ្ឋាន និងលើកទឹកចិត្តគ្រួសារទាំងឡាយតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យឬទិញវាដើម្បីអនុវត្តឥរិយាបថទឹកស្អាតនិងអនាម័យ។ |

**ការរៀបចំ**

- ត្រៀមរៀបចំកម្មវិធីមុនមួយសប្តាហ៍
  - ¤ ណាត់កម្មវិធីមុនមួយសប្តាហ៍
  - ¤ កំណត់ចំនួនមេភូមិដែលចូលរួមវគ្គបណ្តុះបណ្តាល (អនុវត្តតាមការរឹតត្បិតក្នុងស្ថានភាពជំងឺកូវីដ-១៩ដែលណែនាំដោយអាជ្ញាធរឃុំ/ស្រុក/ខេត្ត)
- ការរៀបចំមុនវគ្គបណ្តុះបណ្តាល ២០នាទី
  - ¤ រៀបចំកន្លែងអង្គុយ
  - ¤ រៀបចំតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យសម្រាប់ដាក់បង្ហាញ
  - ¤ ទឹកនិងអាហារសម្រន់

**ឧបករណ៍ /សម្ភារ**

- ក្រដាសណែនាំសង្ខេបពីគម្រោង PHB
- ក្រដាសណែនាំសង្ខេបពីសកម្មភាពផ្លាស់ប្តូរឥរិយាបថផ្នែកទឹកស្អាត និងអនាម័យ (WASH) (ប្រសិនបើមាន)

- USB សម្រាប់ចាក់សម្លេងជាមួយឧបករណ៍បំពងសម្លេងតាមភូមិ
- ឧបករណ៍ទឹកស្អាត និងអនាម័យ (WASH kit)
- ខិត្តប័ណ្ណ
- ស្ទិកគ័រ
- រូបភាពផ្ទាំងធំ (Poster)
- អាវយឺត
- សាប៊ូ
- ទម្រង់សម្រាប់ជ្រើសរើសគ្រួសារគោលដៅ និងប្រមូលលេខទូរស័ព្ទ
- បញ្ជីវត្តមាន
- ម៉ាស់និងអាល់កុល/ជែល។

**ជំហាន៖**

សកម្មភាពទី១៖ ស្វាគមន៍ (៥នាទី)
សកម្មភាពទី២៖ ការណែនាំពីគម្រោង PHB (៣នាទី)
សកម្មភាពទី៣៖ ការណែនាំពីសកម្មភាពនៃការផ្លាស់ប្តូរឥរិយាបថផ្នែកទឹកស្អាត និងអនាម័យ (១០នាទី)
សកម្មភាពទី៤៖ តួនាទីនិងការទទួលខុសត្រូវរបស់មេភូមិ (៥នាទី)
សកម្មភាពទី៥៖ ការជ្រើសរើសគ្រួសារគោលដៅ និងប្រមូលលេខទូរស័ព្ទ (៥នាទី)
សកម្មភាពទី៦៖ ការចាក់ឧបករណ៍បំពងសម្លេង (៥នាទី)
សកម្មភាពទី៧៖ ការតម្លើង និងបង្ហាញឧបករណ៍ទឹកស្អាតនិងអនាម័យ (១៥នាទី)
សកម្មភាពទី៨៖ ពន្យល់ពីខិត្តប័ណ្ណ និងអនុវត្តការតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យ (៣០នាទី)
សកម្មភាពទី៩៖ ការជូនខិត្តប័ណ្ណ និងស្លាកសាប៊ូ (៣នាទី)
សកម្មភាពទី១០៖ ការចុះពិនិត្យដល់ផ្ទះ (៥នាទី)
សកម្មភាពទី១១៖ ការជូនសាប៊ូនិងយកលេខទូរស័ព្ទ (២នាទី)
សកម្មភាពទី១២៖ បញ្ចប់ (១២នាទី)

**ជំហានលម្អិត៖**

| សកម្មភាពទី១៖ ស្វាគមន៍ (៥នាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| អង្គុយជារង្វង់ដោយរក្សាគម្លាត ណែនាំខ្លួននិងអរគុណសម្រាប់ការចូលរួមរបស់ពួកគាត់ | សួស្តីបងប្អូនទាំងអស់គ្នា ខ្ញុំឈ្មោះ.............................. មកពីអង្គការខេមរា។ សូមថ្លែងអំណរគុណចំពោះមេភូមិអស់គ្នា ដែលបានអញ្ជើញចូលរួមកម្មវិធីប្រជុំថ្ងៃនេះ។ |
| អនុញ្ញាតឱ្យពួកគាត់ដឹងពីការរំពឹងទុកក្នុងការចូលរួម ជូនដំណឹងពួកគាត់ដឹងថាការប្រជុំនឹងចំណាយពេលប្រហែល២ម៉ោង | យើងនឹងចំណាយពេលវេលាជាមួយគ្នានៅទីនេះ។ វគ្គនេះគឺមានរយៈពេលប្រហែល២ម៉ោងហើយយើងនឹងមានឱកាសក្នុងការអនុវត្តនិងតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យដូចដែលបានដាក់តាំងនេះស្រាប់។ ជាកិច្ចបន្ទាប់ខ្ញុំនឹងធ្វើការបង្ហាញជូនបងប្អូនទាំងអស់គ្នាអំពីគម្រោងលើកកម្ពស់ឥរិយាបថប្រកបសុខុមាលភាព (PHB) និងសកម្មភាពនៃការផ្លាស់ប្តូរឥរិយាបថសង្គមផ្នែកទឹកស្អាត និងអនាម័យដែលមានគោលបំណងចង់ធ្វើការផ្លាស់ប្តូរឥរិយាបថប្រជាជនក្នុងសហគមន៍ឱ្យមានសុខភាពល្អដូចការងារដែលលោកមេភូមិទាំងអស់គ្នាកំពុងធ្វើរាល់ថ្ងៃអីចឹងដែរ។ ខ្ញុំដឹងហើយថាលោកមេភូមិមានការយកចិត្តទុកដាក់ជាខ្លាំងចំពោះសុខទុក្ខរបស់ប្រជាពលរដ្ឋក្នុងភូមិ។ មេភូមិគឺដូចជាឪពុកម្តាយ។ |



| | |
|---|---|
| | • មែនទេ?<br>ប្រជាពលរដ្ឋគោរពជឿជាក់ និងធ្វើតាមការណែនាំរបស់បងៗ។ យើងខ្ញុំពិតជាស្ញប់ស្ញែងពេញចិត្តការងាររបស់បងៗ ហើយចង់ឱ្យបងៗបន្តការងារនេះហើយក្រុមការងារយើងមកថ្ងៃនេះ គឺចង់ពាំនាំនូវវិធីថ្មីមួយដែលបងៗអាចធ្វើការជាមួយក្រុមគោលដៅ ដើម្បីផ្លាស់ប្តូរឥរិយាបថរបស់ពួកគាត់លើការងារផ្នែកទឹកស្អាត និងអនាម័យដែលអ្នកខ្លះគេហៅកាត់ថា វ៉ស (WASH)។ យើងនឹងចូលរួមសប្បាយទាំងអស់គ្នាជាមួយនឹងការតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យ និងសារគន្លឹះសំខាន់ៗដែលត្រូវយកទៅអនុវត្តក្នុងជីវិតរស់នៅប្រចាំថ្ងៃ។<br>• តើបងៗមានអារម្មណ៍យ៉ាងម៉េចដែរ? |
| ការណែនាំស្គាល់គ្នាទៅវិញទៅមក | ខ្ញុំគិតថាមុនពេលយើងចាប់ផ្តើមវគ្គបណ្តុះបណ្តាលរបស់យើង។ យើងគួរតែស្គាល់គ្នាទៅវិញទៅមកឱ្យកាន់តែច្បាស់សិន។ ដូច្នេះសូមប្រាប់ពីឈ្មោះនិងប្រាប់ដោយស្មោះត្រង់ផងដែរថា តើបងៗលាងសម្អាតដៃនឹងសាប៊ូញឹកញាប់ប៉ុណ្ណា? នៅពេលណាខ្លះ? ខ្ញុំនឹងចាប់ផ្តើមមុនគេហើយបន្ទាប់មក......! |

| សកម្មភាពទី២៖ ការណែនាំពីគម្រោង PHB (៣ នាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| ចាប់ផ្តើមធ្វើការបង្ហាញពីឈ្មោះគម្រោង | យើងស្គាល់គ្នាហើយ។ ឥឡូវខ្ញុំ នឹងចាប់ផ្តើមធ្វើការបង្ហាញពីគម្រោងឈ្មោះគម្រោងលើកកម្ពស់ឥរិយាបថប្រកបដោយសុខុមាលភាពហៅកាត់ថា PHB តើបងប្អូនយល់ឃើញថាម៉េចដែរពេលលឺឈ្មោះគម្រោងនេះ? |
| ការណែនាំអំពីគម្រោង PHB តាមរយៈស្លាយឬវីដេអូខ្លីអំពីទិដ្ឋភាពទូទៅនៃគម្រោងបង្ហាញក្រដាសណែនាំសង្ខេបអំពីគម្រោង និងបញ្ជាក់លើចំណុចសំខាន់ៗ (ប្រសិនបើអាច) | ខ្ញុំចង់ជម្រាបបងៗ ជ្រាបថាគម្រោងលើកកម្ពស់ឥរិយាបថប្រកបដោយសុខុមាលភាព (PHB) គឺមានរយៈពេល៥ឆ្នាំដែលទទួលបានមូលនិធិពីទីភ្នាក់ងារសហរដ្ឋអាមេរិចសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ដែលដឹកនាំអនុវត្តដោយអង្គការអន្តរជាតិបំរើសុខភាពប្រជាជន (PSI)។<br>គម្រោង PHB គឺមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវឥរិយាបថសុខភាពក្នុងចំណោមប្រជាជនកម្ពុជា និងគាំទ្រនូវគោលដៅរបស់ USAID កម្ពុជាដើម្បីធានាថាប្រជាជនកម្ពុជាស្វែងរកនិងទទួលបាននូវការថែទាំសុខភាពប្រកបដោយគុណភាពដោយកាត់បន្ថយនូវការចំណាយផ្សេងៗតាមរយៈប្រព័ន្ធដែលមាននិរន្តរភាព។ សម្រាប់នៅខេត្តត្បូងឃ្មុំនេះគឺសកម្មភាពនៃកម្មវិធី នឹងត្រូវអនុវត្តដោយអង្គការខេមរា។<br>គម្រោងគឺមានកិច្ចសហប្រតិបត្តិការសំខាន់ៗដូចជាក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ក្រសួងសុខាភិបាល (MOH) និងមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព (NCHP)។ ដូចដែលបងៗបានឃើញនៅក្នុងក្រដាសសង្ខេបនេះ |

| | |
|---|---|
| | គម្រោង PHB ផ្តោតលើផ្នែកសុខភាពសំខាន់ៗ៦គឺ៖<br>1. ពន្យារកំណើត<br>2. សុខភាពមាតា និងទារក<br>3. អាហារូបត្ថម្ភ<br>4. ទឹកស្អាត និងអនាម័យ<br>5. ជំងឺរបេង<br>6. ជំងឺគ្រុនចាញ់<br><br>ដែលមានតំបន់គោលដៅនៅ៖<br>1. កំពង់ឆ្នាំង<br>2. កំពង់ចាម<br>3. ត្បូងឃ្មុំ<br>4. បាត់ដំបង<br>5. ប៉ៃលិន<br>6. ភ្នំពេញ<br><br>សម្រាប់ខេត្ត ត្បូងឃ្មុំ ពេលនេះគឺយើងនឹងផ្តោតលើការងារផ្នែកទឹកស្អាតនិង អនាម័យដែលនឹងអនុវត្តដោយអង្គការខេមរា។ |
| ទុកពេលអ្នកចូលរួមសួរសំណួរ | តើបងៗមានសំណួរអ្វីដែរឬទេ? ប្រសិនមិនមានទេខ្ញុំនឹងបង្ហាញបន្តពីសកម្មភាព នៃការផ្លាស់ប្តូរឥរិយាបថសង្គមផ្នែកទឹកស្អាត និងអនាម័យ។ |

## សកម្មភាពទី៣៖ ការណែនាំពីសកម្មភាពនៃការផ្លាស់ប្តូរឥរិយាបថផ្នែកទឹកស្អាត និងអនាម័យ(១០នាទី)

| ធ្វើ | និយាយ |
|---|---|
| ទាញការចូលរួមដោយអនុញ្ញាតឱ្យ អ្នកចូលរួមធ្វើការចែករំលែក ខ្លីអំពីបទ ពិសោធន៍ទាក់ទងនឹងការងារទឹក ស្អាតនិងអនាម័យ<br>អរគុណពួកគេសម្រាប់ការចែក រំលែក | ឥឡូវខ្ញុំនឹងជជែកអំពីសកម្មភាពនៃការផ្លាស់ប្តូរឥរិយាបថផ្នែកទឹកស្អាតនិង អនាម័យ WASH។<br><br>តើបងៗធ្លាប់ធ្វើការ ឬចូលរួមសកម្មភាពទាក់ទងនឹងសកម្មភាព នៃការផ្លាស់ប្តូរ ឥរិយាបថសង្គមផ្នែកទឹកស្អាតនិងអនាម័យ WASH ហ្នឹងពីមុនមកទេ?<br><br>ប្រសិនបើមាន តើមានអ្នកស្ម័គ្រចិត្តចង់ចែករំលែកពីការងារទេ?<br>ពិតជាអស្ចារ្យណាស់។ សូមអរគុណសម្រាប់ការងារដ៏មានសារសំខាន់ និងបាន ចែករំលែកមកក្រុម។ |



| | |
|---|---|
| ចែករំលែកពីបរិបទនៃការងារ ទឹកស្អាតនិងអនាម័យនៅ ប្រទេសកម្ពុជា<br><br>ធ្វើឱ្យមានការចូលរួមពីពួកគាត់អំពី ទឹកស្អាតនិងអនាម័យ | ខ្ញុំគិតថាមានបងៗមួយចំនួនធ្លាប់បានដឹង/លឺអំពីបញ្ហានេះហើយ។ ខ្ញុំចង់ដក ស្រង់ចំណុចសំខាន់ៗមួយចំនួនដែលទាក់ទងនឹងផ្នែកទឹកស្អាត និងអនាម័យ វិសេស។ តែខ្ញុំចង់សួរបងៗបន្តិចសិន។<br><br>• តើពាក្យថាទឹកស្អាតនិងអនាម័យមានន័យដូចម្តេចទៅ?<br>សូមអរគុណសម្រាប់ការចែករំលែក។<br>នៅពេលដែលយើងនិយាយពីទឹកស្អាត និងអនាម័យ។ បាទ/ចាសគឺមានចំណុច ៣សំខាន់ដែលត្រូវផ្តោតទៅលើគឺការលាងសម្អាតដៃ នឹងសាប៊ូ ហូបទឹកសុវត្ថិភាព និងការប្រើបង្គន់អនាម័យ។សម្រាប់សកម្មភាពនៃការផ្លាស់ប្តូរឥរិយាបថសង្គម ផ្នែកទឹកស្អាត និងអនាម័យដែលយើងកំពុងចាប់អនុវត្តនេះ គឺផ្តោតសំខាន់តែ២ ទេគឺទី១លាងសម្អាតដៃនឹងសាប៊ូ និង ទី២ហូបទឹកដែលបានដាំ ឬចម្រោះ និង រក្សាទុកដោយសុវត្ថិភាព។<br>• តើបងៗធ្លាប់អង្កេតមើលឥរិយាបថទឹកស្អាត និងអនាម័យទាំងពីរខាងលើ នៅក្នុងសហគមន៍របស់បងទេ?<br>• តើបងអាចធ្វើការចែករំលែកបានទេ?<br>សូមអរគុណសម្រាប់ការចែករំលែកចំណុចទាំងនេះ។<br>យោងតាមការសិក្សារបស់ PHB នៅក្នុងខេត្តគោលដៅបានបង្ហាញថាប្រជាជន ប្រមាណ៧១% លាងសម្អាតដៃនឹងសាប៊ូក្រោយពេលបន្ទោបង់ខណ:ដែលការ លាងសម្អាតដៃនឹងសាប៊ូនៅពេលវេលាសំខាន់ៗដទៃទៀតបានតែ ២២,៧% ប៉ុណ្ណោះគឺទាបមែនទែន។លើសពីនេះទៀតគ្រួសារនៅទីជនបទប្រមាណ៣១% បានប្រើប្រើប្រាស់វិធីផ្សេងៗដើម្បីបន្សុទ្ធទឹកដូចជាការដាំទឹក ដាក់សារធាតុធ្វើឱ្យ ថ្លានិងចម្រោះ។<br><br>យើងត្រូវធ្វើការកែប្រែឥរិយាបថទាំងនេះឱ្យមានភាពប្រសើរឡើង!<br>យើងបានលើកអំពីទឹកហូបដោយសុវត្ថិភាព និងការលាងសម្អាតដៃនឹង សាប៊ូ។<br>• តើយើងធ្វើដូចម្តេចដើម្បីទទួលបានទឹកសុវត្ថិភាព?<br>សូមជួយចែករំលែកមក!<br>• ចុះការលាងសម្អាតដៃ នឹងសាប៊ូវិញយ៉ាងម៉េចដែរ?<br>• តើការលាងសម្អាតដៃ នឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង៥ មាន អ្វីខ្លះទៅ?<br>សូមជួយប្រាប់ផង! សូមអរគុណសម្រាប់ការចូលរួម។<br>បាទ/ចាសពេលវេលាសំខាន់ៗទាំង ៥គឺមានដូចជា៖<br>1. មុនពេលធ្វើម្ហូប ឬប៉ះគ្រឿងម្ហូបអាហារ<br>2. មុនពេលបរិភោគ<br>3. មុនពេលបញ្ចុកក្មេង<br>4. បន្ទាប់ពីបន្ទោបង់<br>5. លាងសម្អាតគូទទារក |

| | |
|---|---|
| | ខ្ញុំគិតថាបងៗទទួលបានអ្វីៗទាំងអស់ដែលយើងកំពុងធ្វើនិងមូលហេតុដែលយើងមកថ្ងៃនេះ។បងៗគឺជាបុគ្គលដែលសំខាន់បំផុតដែលស្គាល់ប្រជាពលរដ្ឋរបស់បងៗនៅក្នុងសហគមន៍នេះ។ មូលហេតុនេះដែលបងៗគឺជាធនធានដ៏មានតម្លៃក្នុងសកម្មភាពនៃការផ្លាស់ប្តូរឥរិយាបថសង្គមផ្នែកទឹកស្អាត និងអនាម័យដូច្នេះហើយយើងខ្ញុំត្រូវការបងៗ ចូលរួមការអន្តរាគមន៍នេះជាចាំបាច់។<br><br>• តើបងៗពិតជាចង់ជួយប្រជាជនរបស់បងៗឱ្យមានសុខភាពល្អដែរឬទេ? |

## សកម្មភាពទី៤៖ តួនាទី និងការទទួលខុសត្រូវរបស់មេភូមិ(១០ នាទី)

| ធ្វើ | និយាយ |
|---|---|
| ប្រាប់ពីតួនាទីទទួលខុសត្រូវរបស់ពួកគាត់<br><br>ទុកពេលពួកគាត់សួរបញ្ជាក់និងសំណួរផ្សេងៗទៀត<br><br>ឆ្លើយនឹងសំណួររបស់ពួកគេ(សំណួរដែលទាក់ទងនឹងវគ្គបន្ទាប់សូមឱ្យពួកគាត់រង់ចាំ) | ដូចដែលបងៗបានឆ្លើយហើយថា «ជួយ» ប្រជាជនសហគមន៍។បាទ/ចាសខ្ញុំចង់ជម្រាបនូវសកម្មភាពការងារសំខាន់ៗ ដែលបងៗអាចធ្វើការចាត់ចែងនិងដឹកនាំមានដូចខាងក្រោម។<br>តួនាទីរបស់មេភូមិត្រូវធ្វើ៖<br>• ចុះជ្រើសរើសគ្រួសារគោលដៅ(មិនមានឧបករណ៍ទឹកស្អាត និងអនាម័យ) និងប្រមូលលេខទូរស័ព្ទរបស់មេគ្រួសារ និងផ្ញើមកក្រុមការងារយើងខ្ញុំ (IPC)<br>• រៀបចំ និងចាក់ឧបករណ៍បំពងសម្លេងនៅក្រៅផ្ទះរបស់បងៗ<br>• ដាក់តាំង/ចែកខិត្តប័ណ្ណ<br>• តម្លើង និងដាក់បង្ហាញឧបករណ៍ទឹកស្អាត និងអនាម័យក្រៅផ្ទះដើម្បីឱ្យគេមើលឃើញ<br>• ស្តុកសាប៊ូ<br>• ចុះពិនិត្យតាមផ្ទះអ្នកដែលតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យ<br>¤ ត្រួតពិនិត្យការតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យថាត្រឹមត្រូវ<br>¤ ជូនសាប៊ូដុំចំនួន២ឥតគិតថ្លៃ និងស្ទិកគ័របិទទៅគ្រួសារដែលតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យបានត្រឹមត្រូវ<br>- ជូនតែសាប៊ូដុំចំនួន២ទេចំពោះគ្រួសារដែលបានទិញ និងតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យបានត្រឹមត្រូវព្រោះគាត់បានទទួលស្ទិកគ័រពីអ្នកលក់រួចហើយ<br>¤ កត់ឈ្មោះ និងលេខទូរស័ព្ទគ្រួសារដែលបានជូនសាប៊ូនោះ<br>យើងនឹងធ្វើបណ្តុះបណ្តាលបងៗលើការងារទាំងនេះហើយ នឹងនៅចាំជួយបងៗពីខាងក្រោយ។<br>• តើបងប្អូនមានសំណួរ ឬមានអ្វីចង់បញ្ជាក់ដែរទេ? |



## សកម្មភាពទី៥៖ ការជ្រើសរើសគ្រួសារគោលដៅ និងប្រមូលលេខទូរស័ព្ទ(៥ នាទី)

| ធ្វើ | និយាយ |
|---|---|
| ប្រាប់ពីការងារទីមួយរបស់ពួកគាត់ ពន្យល់ពីការជ្រើសរើសគ្រួសារគោលដៅ<br><br>ការជូនខិត្តប័ណ្ណ | យើងបានជជែកគ្នាពីខាងលើមក១/ការលាងសម្អាតដៃឬកន្លែងលាងសម្អាតដៃ២/ដាំឬចម្រោះ និងការរក្សាទុកឱ្យមានសុវត្ថិភាព។<br>• តើបងអាចប្រាប់បានទេថា តើមានប៉ុន្មានគ្រួសារនៅក្នុងភូមិ ដែលមានឧបករណ៍អនាម័យទាំងពីរប្រភេទនេះប្រើ ឧបករណ៍លាងសម្អាតដៃនិងឧបករណ៍ដាំឬចម្រោះទឹកនិងរក្សាទឹកហូប?<br>• តើបងៗធ្លាប់អង្កេតមើល និងបានប្រមូលព័ត៌មានទាំងនេះទេ?<br>• តើបងៗមានលេខទំនាក់ទំនងរបស់មេគ្រួសារទាំងអស់ក្នុងភូមិទេ?<br>អរគុណច្រើន<br>**ការងារសំខាន់ដំបូង** របស់បងៗគឺពិនិត្យ និងជ្រើសរើសគ្រួសារណាដែលមិនទាន់មានឧបករណ៍ទឹកស្អាត និងអនាម័យទាំងនោះប្រើប្រាស់នៅឡើយហើយយកលេខទូរស័ព្ទនៃមេគ្រួសារទាំងនោះ (ប្តី ឬប្រពន្ធដែលចេះទទួលសារសម្លេងតាមទូរស័ព្ទ និងអាចឆ្លើយតបតាមទូរស័ព្ទជាមួយភ្នាក់ងារអប់រំ របស់យើង)។<br>មិនអីទេ ចាំខ្ញុំបញ្ជាក់បន្ថែមលើការងារនេះ។<br>**ជំហានទី១៖** ចុះទៅតាមផ្ទះ ហើយអង្កេតមើលប្រសិនបើផ្ទះនោះមានកន្លែងលាងសម្អាតដៃដោយមានសាប៊ូនិងទឹក និងធុងសម្រាប់ដាក់ទឹកហូបស្អាត<br>• កន្លែងលាងសម្អាតដៃ<br>¤ ធុងទឹក/ពាងតូចមានក្បាលរ៉ូប៊ីណេ (មិនប្រើបោយដងទឹក) ដែលប្រើសម្រាប់លាងសម្អាតដៃប៉ុន្តែ មិនមែនប្រើសម្រាប់ហូបទេនិងមានកន្លែងបង្ហូរទឹក<br>ចោល/កន្ទន់ត្រងទឹកកខ្វក់ដែលលាងដៃហើយ<br>¤ សាប៊ូ និងថង់សំណាញ់សម្រាប់ដាក់<br>¤ ពួកគាត់ត្រូវមានឈុតឧបករណ៍ខាងលើពីរ គឺមួយដាក់នៅផ្ទះបាយនិងមួយទៀតនៅក្រៅបង្គន់<br>• ឧបករណ៍ទឹកស្អាត<br>¤ ឧបករណ៍សម្រាប់ដាំ ឬចម្រោះទឹកដូចជាកំសៀវ ឬឆ្នាំងឬ ធុងចម្រោះ<br>¤ ធុងដាក់ទឹកហូបដូចជាធុង/ដបទឹកស្អាតមានគម្រប និងងាយស្រួលលាងសម្អាត ដែលត្រូវមានយ៉ាងហោចណាស់២ ហើយមានសញ្ញាឡូហ្គោ PETE 1នៅលើធុង ឬដបនោះ។<br>**ជំហានទី២៖** ប្រសិនបើពួកគាត់មិនមានឧបករណ៍ទាំងអស់នេះទេមានន័យថាពួកគាត់ត្រូវលក្ខខណ្ឌដែលត្រូវជ្រើសរើស គឺត្រូវកត់ត្រាផ្ទះនោះក្នុងបញ្ជី ហើយសុំលេខទូរស័ព្ទមេគ្រួសារ។<br>• សូមសួរម្ចាស់ទូរស័ព្ទផងថា៖ តើពួកគាត់យល់ព្រមទេបើយើងផ្ញើសារសុខភាពស្តីពីទឹកស្អាត និងអនាម័យទៅទូរស័ព្ទរបស់ពួកគាត់? |

| | |
|---|---|
| | • ជូនខិត្តប័ណ្ណ<br>(ប្រសិនបើពួកគាត់មានឧបករណ៍ទឹកស្អាត និងអនាម័យប្រើសព្វគ្រប់ហើយ មានន័យថាពួក គេមិនត្រូវលក្ខខណ្ឌជ្រើសរើសទេ។<br>សូមរំលឹកពួកគេពីការអនុវត្តការលាង សម្អាតដៃនៅពេលវេលាសំខាន់ៗទាំង៥ និងហូបទឹកដែលបានដាំ ឬចម្រោះ និងរក្សាទុកឱ្យមានសុវត្ថិភាព)។<br><br>**ជំហានទី៣៖** បន្ទាប់ពីបានជ្រើសរើសគ្រួសារក្នុងភូមិអស់ហើយសូមយកឈ្មោះ និងលេខទូរស័ព្ទទាំងនោះប្រគល់មកភ្នាក់ងារអប់រំ IPC (ខេមរា)។<br>• តើបងៗទទួលបានអ្វីដែលខ្ញុំជម្រាបជូននេះទេ?<br>ល្អណាស់! |

## សកម្មភាពទី៦៖ ការចាក់ឧបករណ៍បំពងសម្លេង(៥ នាទី)

| ធ្វើ | និយាយ |
|---|---|
| ប្រាប់ពួកគាត់ពីការងារទីពីរ គឺចាត់ចែងចាក់<br>សារអប់រំតាមឧបករណ៍បំពងសម្លេង | ការងារសំខាន់ទីពីររបស់បងៗគឺចាត់ចែងចាក់ឧបករណ៍បំពងសម្លេង (មេក្រូ ឬ បាស) ពីផ្ទះរបស់បងពីព្រោះ យើងនឹងជូនឧបករណ៍ទឹកស្អាត និងអនាម័យ ហើយបងរៀបចំតម្លើងវានៅផ្ទះហើយយើងនឹងជជែកបន្ថែមបន្តិចទៀតនេះ។<br><br>នេះជាពេលវេលាសំខាន់មួយដែលត្រូវផ្តល់ការយល់ដឹងពីផ្នែកទឹកស្អាត និង អនាម័យទៅកាន់ប្រជាពលរដ្ឋសហគមន៍។<br>យើងនឹងជូនUSB ដែលបានថតសារសម្លេងស្រេចដើម្បីចាក់។<br>• តើប្រដាប់ចាក់របស់បងអាចប្រើ USBបានទេ?<br>¤ បាទ/ចាសសារនឹងនិយាយពីការលាងសម្អាតដៃ និងហូបទឹកដែលមាន សុវត្ថិភាពនិងឧបករណ៍ទឹកស្អាត និងអនាម័យផងដែរ។<br><br>យើងមានពេលវេលាកំណត់ហើយកម្មវិធីសម្រាប់បងៗចាក់សម្លេង គឺដូចខាង ក្រោម។<br>• ចាក់មួយថ្ងៃ៣ដង<br>• ចាក់តែចំនួន១០ថ្ងៃប៉ុណ្ណោះក្នុងរយៈពេល ២ខែ<br>¤ នៅចំណុចនេះបងអាចចាត់ចែងការចាក់រកមើលពេលណាដែលល្អ បំផុត ។បងត្រូវប្រាកដថាចាក់ចំពេលដែលមនុស្សនៅផ្ទះហើយអាច ទទួលបានសារដែលចាក់នោះ។<br>¤ ភូមិនីមួយៗអាចមានភាពស្ថានភាពខុសគ្នា ហើយបងដឹងច្បាស់ពីភូមិខ្លួន ឯងហើយ ។មែនទេ?ទាក់ទងនឹងការចាក់ឧបករណ៍បំពងសម្លេងនេះ<br>• តើបងៗមានអ្វីចង់សួរបញ្ជាក់ទេ? |



## សកម្មភាពទី៧៖ ការតម្លើង និងដាក់បង្ហាញឧបករណ៍ទឹកស្អាត និងអនាម័យ(១៥ នាទី)

| ធ្វើ | និយាយ |
|---|---|
| យកឧបករណ៍ទឹកស្អាតនិង អនាម័យ<br><br>សួរពួកគាត់នូវសំណួរមួយចំនួន ទាក់ទងនឹងឧបករណ៍ទឹកស្អាត និងអនាម័យ<br><br>ប្រាប់ពួកគាត់ពីគោលបំណង<br><br>ជូនដំណឹងឱ្យពួកគាត់ដឹងថាពួកគេ នឹងទទួលបានមួយឈុត នៃឧបករណ៍ទឹកស្អាតនិង អនាម័យសម្រាប់ដាក់តាំង បង្ហាញនៅផ្ទះចំពោះការចូល រួមក្នុងកម្មវិធី | បាទ/ចាសបងៗ មួយចំនួនបានក្រឡេកមើលទៅឧបករណ៍ដែលដាក់តាំង។<br>• តើបងគិតដូចម្តេចដែរពេលបានឃើញឧបករណ៍ទាំងនេះ? (រំលឹកពួកគេ អំពីអនាម័យ....)<br>• តើបងមានអារម្មណ៍យ៉ាងណាចំពោះឧបករណ៍ទាំងនេះ? (មើលទៅស្អាត ស្រួលប្រើជំរុញចិត្ត...)<br>• តើឧបករណ៍ទាំងនេះប្រើសម្រាប់ធ្វើអ្វីដែរ? (ទុកទឹក...)<br>¤ មួយនេះនិងមួយនោះ?<br>• តើបងមានឧបករណ៍ហ្នឹងប្រើនៅផ្ទះទេ?<br>¤ មិនអីទេបើទោះជាម៉ាកខុសគ្នា ឬរូបរាង ឬទំហំ<br>• តើយើងហៅរបស់ទាំងនេះថាយ៉ាងម៉េច?<br>សូមអរគុណសម្រាប់ការចូលរួម។<br>បាទ/ចាសទាំងនេះគឺជាឧបករណ៍ទឹកស្អាត និងអនាម័យ។<br>គុណសម្បត្តិនៃការមានឧបករណ៍ទឹកស្អាត និងអនាម័យទាំងនេះគឺ៖<br>• កន្លែងលាងសម្អាតដៃមានក្បាលរ៉ូប៊ីណេ គឺវាងាយស្រួលប្រើប្រាស់ហើយ ស្អាតជាងការប្រើបោយដងទឹក<br>• ក្មេងៗក៏អាចលាងសម្អាតដៃដោយខ្លួនឯងបានផងដែរ<br>• កាលដែលមានធុងដាក់ទឹកហូបចំណុះ២០លីត្រចំនួន២គឺមិនដែល អស់ទឹកហូប<br>• មានកន្លែងលាងសម្អាតដៃ និងធុងដាក់ទឹកហូបធំៗមានន័យថាអ្នកមាន ពេលវេលាច្រើនជាមួយគ្រួសារ<br>• ទទួលបានសាប៊ូដោយឥតគិតថ្លៃហើយ «ពិសេស» ស្ទិកគ័រដ៏ស្រស់ស្អាត សម្រាប់បិទរំលឹកពីការអនុវត្តឥរិយាបថទឹកស្អាត និងអនាម័យទៀតផង<br>ខ្ញុំនឹងប្រាប់លម្អិតពីឧបករណ៍ទាំងនេះ។<br>ផ្នែកខាងនេះគឺជាឧបករណ៍សម្រាប់លាងសម្អាតដៃ។<br>ឧបករណ៍អនាម័យផ្នែកលាងសម្អាតដៃរួមមាន៖<br>• ក្បាលរ៉ូប៊ីណេចំនួន២<br>• ស្ទិកគ័របិទចំនួន ២ឈុត<br>គ្រួសារទាំងឡាយត្រូវមានធុងទឹកខ្លួនឯងដែលមានគម្រប និងកន្ទន់ត្រងទឹក កខ្វក់។ប្រសិនបើពួកគាត់មិនមានរបស់ទាំងនេះទេពួកគាត់អាចទិញពីអ្នកលក់ គ្រឿងប្លាស្ទិចដែលនៅជិតបំផុតក៏បាន។<br>សូមពិនិត្យមើលធុងទាំងនេះម្តងទៀត។<br>• តើវាមានបញ្ហាអ្វីអត់?<br>ជាការពិតគ្រប់ផ្ទះត្រូវតែមានឧបករណ៍លាងសម្អាតដៃ២ឈុតដែលមួយដាក់ |

<table>
<tr><td></td><td>នៅផ្ទះបាយនិងមួយទៀតដាក់នៅក្រោយបង្គន់ដូច្នេះហើយបានជាគេបិទស្ទិកគ័រខុសគ្នា។<br>● តើស្ទិកគ័រនីមួយៗនៅលើធុងនឹងប្រាប់យើងថាម៉េច?<br>បាទ/ចាសវាប្រាប់ថា«មើលឃើញស្អាតមិនប្រាកដថាមានសុវត្ថិភាពទេ»។<br>● ហេតុអ្វី?<br>ពីព្រោះយើងមិនអាចមើលមេរោគឃើញទេដូច្នេះហើយយើងត្រូវតែលាងសម្អាតដៃរបស់យើងនឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង៥ដើម្បីធានាថាវាមានសុវត្ថិភាព។<br>● តើបងៗចាំទេពេលវេលាសំខាន់ៗទាំង៥គឺនៅពេលណាខ្លះទៅ?<br>ពេលវេលាទាំងនោះគឺមានបិទនៅលើធុងនេះស្រេចហើយ។ មួយនេះ៖<br>● តើគេប្រាប់អ្វីខ្លះ?<br>បាទ/ចាសលាងសម្អាតដៃនឹងសាប៊ូមុនពេលធ្វើម្ហូបបញ្ចុកក្មេង និងបរិភោគ<br>● ចុះនៅលើធុងមួយនេះវិញ?<br>លាងសម្អាតដៃនឹងសាប៊ូក្រោយពេលសម្អាតគូទទារក និងបន្ទោបង់។<br>● តើបងៗយល់ពីសារអប់រំនៅលើស្ទិកគ័រទាំងនេះហើយមែនទេ?<br>● តើបងៗគិតយ៉ាងដូចម្ដេចដែរចំពោះសារទាំងនេះ?<br>យើងនឹងអនុវត្តនិងតម្លើងឧបករណ៍លាងសម្អាតដៃនេះទាំងអស់គ្នាដោយមើលគំរូតាមខិត្តប័ណ្ណណែនាំនេះ។<br>ផ្នែកទឹកស្អាត គឺឧបករណ៍ដាក់ទឹកសុវត្ថិភាពមានដូចជា៖<br>● ធុង(ដប)ទឹកចំណុះ ២០លីត្រដែលមានគម្រប និងក្បាលរ៉ូប៊ីណេចំនួន២ (ឬធុងធំផ្សេងទៀតដែលមានគម្រប និងក្បាលរ៉ូប៊ីណេ និងមានដាក់ PETE 1)<br>● ស្ទិកគ័របិទ ២ឈុត<br>ក្រឡេកមើលស្ទិកគ័រទាំងនេះ គឺវាបង្ហាញពីការដាំ ឬចម្រោះនិងរក្សាទុកទឹកហូបឱ្យមានសុវត្ថិភាព។<br>● ហេតុអ្វីបានជាស្ទិកគ័រទាំងពីរលើធុងទឹកដូចគ្នា? វាខុសពីស្ទិកគ័រដែលបិទលើធុងលាងសម្អាតដៃ ដែលខុសគ្នា។<br>● តើបងៗយកអ្វីច្រកទឹកហូបនៅផ្ទះ?<br>● សម្រាប់បងៗដែលប្រើធុងទឹក តើបងមានធុងទឹកនឹងប៉ុន្មាន?<br>¤ តើធុងទឹកប៉ុណ្ណឹងល្មមគ្រប់ប្រើទេ?<br>● តើបងគិតថាគួរមានធុងប៉ុន្មាន?<br>បាទ/ចាស<br>ត្រូវមានធុងដាក់ទឹកហូបយ៉ាងហោចណាស់ចំនួន២។ ធ្វើតាមរបៀបនេះទាំងធុង និងទឹកគឺតែងតែស្អាតជានិច្ច............ជាការពិតយើងចង់ឱ្យតាមផ្ទះនីមួយៗមានធុងទឹកយ៉ាងហោចណាស់២ដូច្នេះ ពួកគាត់អាចដូរ(ឆ្លាស់)ធុងទឹកប្រើបាន និងលាងសម្អាតនឹងសាប៊ូផងដែរ។<br>● តើវាមានន័យយ៉ាងម៉េច? សូមមើលស្ទិកគ័រនៅលើធុងទឹកនេះ។<br>● តើមានបងណាអាចជួយអានដំណើរការនេះបានទេ?</td></tr>
</table>



<table>
<tr><td></td><td>សូមអរគុណ<br>វាបានប្រាប់យើងពីដំណើរការដើម្បីទទួលបានទឹកសុវត្ថិភាពសម្រាប់ហូប។<br>● លាងសម្អាតធុងទឹកនឹងសាប៊ូ<br>● ដាំ ឬចម្រោះទឹក<br>● ទុកទឹកឱ្យត្រជាក់ ហើយចាក់ចូលក្នុងធុង<br>● ហូបទឹកនោះជាមួយកែវដែលស្អាត<br>● នៅពេលទឹកជិតអស់<br>● ធ្វើដំណើរការពីខាងលើសម្រាប់ធុងទឹកទីពីរ (១ដល់៣)<br><br>នៅពេលដែលយើងមានធុងទឹក២នោះយើងនឹងមិនដាច់ឬអស់ទឹកហូបទេហើយយើងអាចធ្វើឱ្យធុងទឹកបានស្អាតជាប្រចាំទៀត។ ប្រសិនបើមានធុងទឹកតែ១<br><br>គឺវាមានការលំបាកក្នុងការច្រកទឹកទុកហូប និងការសម្អាតវា។ បាទ/ចាស វាអាស្រ័យផងដែរ នឹងចំនួនសមាជិកគ្រួសារ។<br>● តើបងៗមានសំណួរអ្វីទេ ឬមានអ្វីចង់បញ្ជាក់?<br><br>មុនពេលដែលយើងតម្លើងធុងលាងសម្អាតដៃនេះ។ ខ្ញុំចង់ឆ្លៀតឱកាសនេះជម្រៀបបងៗទាំងអស់ថាបងៗនឹងទទួលបានឈុតឧបករណ៍ទឹកស្អាតនិងអនាម័យមួយកំប្លេ សម្រាប់ដាក់តម្លើងនៅផ្ទះកាលដែលបងចូលរួមក្នុងកម្មវិធីដើម្បីដាក់តាំងបង្ហាញជាគំរូសម្រាប់ឱ្យប្រជាពលរដ្ឋមើល និងយកគំរូតាម។ ដូច្នេះបងៗត្រូវដឹងពីរបៀបតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យនេះ និងជួយប្រជាពលរដ្ឋក្នុងសហគមន៍បានប្រសិនបើពួកគាត់ត្រូវការ។<br>● តើបងៗរីករាយជាមួយនឹងការងារនេះទេ?</td></tr>
</table>

<table>
<tr><th colspan="2">សកម្មភាពទី៨៖ ពន្យល់ខិត្តប័ណ្ណ និងអនុវត្តការតម្លើងឧបករណ៍លាងសម្អាតដៃ(៣០ នាទី)</th></tr>
<tr><th>ធ្វើ</th><th>និយាយ</th></tr>
<tr><td>ចែកខិត្តប័ណ្ណ</td><td>នេះជាខិត្តប័ណ្ណដែលបង្ហាញពីឧបករណ៍ទឹកស្អាតនិងអនាម័យ។ សូមយកម្នាក់មួយ ។វាជួយបងៗតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យបានយ៉ាងងាយស្រួល នេះសូមមើលទាំងអស់គ្នា!<br><br>ខិត្តប័ណ្ណណែនាំបង្ហាញបងៗពីរបៀបតម្លើងឧបករណ៍លាងសម្អាតដៃ។ សូមមើលវាទៅ។<br>● តើគេប្រាប់អ្វីខ្លះក្នុងខិត្តប័ណ្ណ?<br>● បងឃើញអ្វីខ្លះក្នុងហ្នឹង?<br>● តើគំនូសបង្ហាញក្នុងហ្នឹងមើលយល់ដែរទេ?</td></tr>
</table>

ល្អណាស់យើងនឹងមើលទាំងអស់គ្នាពីទំព័រមុខតែម្តង។ អក្សរចំណងជើងធំខាងលើនេះសរសេរថា «មេរោគទាំងអស់មើលមិនឃើញទេ» ហើយខាងក្រោមសរសេរថា «មើលឃើញស្អាតមិនប្រាកដថាមានសុវត្ថិភាទេ!»

- តើវាជាការពិតទេ? បាទ/ចាសយើងទើបជជែកគ្នារឿងហ្នឹងមុននេះចុះអក្សរនៅខាងក្រោម
- តើគេសរសេរថាម៉េចខ្លះដែរ?
- តើមានបងណាអាចជួយអានបន្តិចបានទេ?

គេប្រាប់ថា«ការពារខ្លួនអ្នកនិងគ្រួសាររបស់អ្នកពីមេរោគទាំងឡាយដោយលាងសម្អាតដៃ នឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង៥ និងហូបទឹកដែលបានដាំឬចម្រោះ និងរក្សាឱ្យមានសុវត្ថិភាពតែប៉ុណ្ណោះ»។

សូមអរគុណសារទាំងនេះរំលឹកយើងឱ្យចេះការពារខ្លួនរបស់យើងពីជំងឺរាកឬជំងឺផ្សេងៗទៀតមែនដែរទេ? បើកទំព័រមុខហ្នឹងឡើងមក!

**បង្ហាញឧបករណ៍/សម្ភារ**

អូ! ឧបករណ៍ទឹកស្អាត និងអនាម័យធ្វើឱ្យមានភាពងាយស្រួល។
ល្អណាស់! ផ្នែកខាងក្នុងខិត្តប័ណ្ណសរសេរថា «ធ្វើកន្លែងលាងសម្អាតដៃដោយខ្លួនឯង» ពិតជាអស្ចារ្យមែន។

- តើយើងត្រូវការអ្វីខ្លះ?

**អានជំហានក្នុងខិត្តប័ណ្ណ និងចាប់ផ្តើមតម្លើង**

ឧបករណ៍លាងសម្អាតដៃត្រូវការក្បាលរ៉ូប៊ីណេចំនួន២ស្ទិកគ័របិទ និងគំរូចោះរន្ធហើយអ្នកក៏ត្រូវការផងដែរ៖

- ធុងទឹកមានគម្របចំនួន២
- ម៉ាស៊ីនស្វាន១
- កន្ទន់ត្រងទឹកកខ្វក់ចំនួន២
- ជើងទម្រសម្រាប់ដាក់ឧបករណ៍លាងសម្អាតដៃចំនួន ២

(ប្រសិនបើអ្នកភូមិមិនមានសម្ភារទាំងនេះ គាត់អាចរកទិញបាន) អ្វីៗគឺនៅទីនេះអស់ហើយ។

ហើយគេបង្ហាញយើងពីជំហានចំនួន១០ដែលយើងអាចធ្វើកន្លែងលាងសម្អាតដៃមួយបានដោយខ្លួនឯង។

1. ដាក់គំរូក្រឹតចោះរន្ធលើធុងផ្នែកខាងក្រោមជិតបាតធុង
2. ប្រើប្រដាប់ស្វានខួងចោះរន្ធ
3. ដាក់ក្បាលរ៉ូប៊ីណេនៅចំណុចដែលបានស្វានលើធុងនោះ (ដាក់ឱ្យវាស៊ីគ្នា)
4. ចោះរន្ធតូចមួយទៀតលើគម្របធុងដើម្បីឱ្យមានខ្យល់ចូល
5. បិទស្ទិកគ័រ «មុនពេល» នៅជ្រុងនៃធុងលាងសម្អាតដៃសម្រាប់ដាក់នៅផ្ទះបាយ និងបិទស្ទិកគ័រ«ក្រោយពេល» នៅលើធុងលាងសម្អាតដៃមួយទៀតសម្រាប់ដាក់នៅក្បែរបង្គន់



6. រៀបចំដាក់ជើងទម្រមួយនៅផ្ទះបាយ ឬកន្លែងហូបបាយហើយមួយទៀតនៅក្រៅបង្គន់
7. ចាក់ទឹកចូលធុងហើយលើកដាក់លើជើងទម្រ
8. គ្របគម្របធុងលាងសម្អាតដៃ
9. ដាក់កន្ទន់ពីក្រោមក្បាលរ៉ូប៊ីណេសម្រាប់ត្រងទឹកកខ្វក់ ហើយនៅមានជំហានចុងក្រោយមួយទៀត

- តើបងៗដឹងទេ?

10. ដាក់សាប៊ូដុំក្នុងថង់សំណាញ់ហើយព្យួរលើក្បាលរ៉ូប៊ីណេ

សាប៊ូ គឺសំខាន់បំផុតនៅក្នុងផ្នែកនេះ! យើងនឹងជូនសាប៊ូដុំចំនួន២ទៅអ្នកដែលតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យបានត្រឹមត្រូវ។ យើងក៏នឹងជូនថង់ដាក់សាប៊ូ២ផងដែរ ដែលអាចព្យួរលើក្បាលរ៉ូប៊ីណេនៃឧបករណណ៍លាងសម្អាតដៃទាំង២។

- តើបងៗដឹងទេថាម៉េចបានជាយើងប្រើថង់សាប៊ូ?

ពីព្រោះជាញឹកញាប់សាប៊ូងាយនឹងរបូតជ្រុះដែលធ្វើឱ្យវាប្រឡាក់។ វិធីនេះនឹងធ្វើឱ្យសាប៊ូនៅតែស្អាត ហើយថង់សំណាញ់នេះជួយឱ្យសាប៊ូកាន់តែមានពពុះច្រើនកាន់តែងាយស្រួលលាងសម្អាតដៃថែមទៀត។ ពេលដែលអស់សាប៊ូដាក់សាប៊ូមួយដុំទៀតចូលទៅ។

- ក្នុងខិត្តប័ណ្ណប្រាប់យើងគ្រប់យ៉ាងដែលយើងត្រូវធ្វើតាម។ តើបងៗគិតថាអាចទៅរកហើយធ្វើវាបានដោយខ្លួនឯងទេ?

តោះ ដំឡើងធុងលាងសម្អាតដៃមួយទាំងអស់គ្នា ដើម្បីបង្ហាញឱ្យច្បាស់ថាវាពិតជាងាយស្រួលពិតប្រាកដមែន។

- តើមានបងណាស្ម័គ្រចិត្តទេ?

(ទុកពេល១៥នាទី សម្រាប់ការតម្លើងធុងលាងសម្អាតដៃមួយ)

..................................................................................................

ឥឡូវបងៗបានដឹងពីសារៈប្រយោជន៍នៃឧបករណ៍ទឹកស្អាត និងអនាម័យនិងរបៀបធ្វើវាហើយ។
យើងចង់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋធ្វើការតម្លើងឧបរកណ៍ទឹកស្អាតនិងអនាម័យដោយខ្លួនឯងហើយប្រសិនបើពួកគាត់មិនមានឧបករណ៍/សម្ភារឬក៏ចាប់អារម្មណ៍ និងចង់ទិញឧបករណ៍ដែលតម្លើងស្រេចពួកគាត់អាចទំនាក់ទំនងទៅអ្នកលក់ដោយផ្ទាល់តាមរយៈលេខក្នុងប្រអប់នេះ។

| |
|---|
| លោក................. លេខទំនាក់ទំនង............................................ |

សូមសរសេរឈ្មោះនិងលេខទូរស័ព្ទអ្នកលក់ឧបករណ៍ទឹកស្អាតនិងអនាម័យដែលនៅជិតបំផុតដែលបានឱ្យទៅបងក្នុងខិត្តប័ណ្ណនេះ។
ពួកគាត់ក៏អាចសួរបងៗឱ្យពន្យល់ពួកគាត់ពីរឿងទាំងនេះផងដែរ

- តើយ៉ាងម៉េចដែរ?

ហើយមួយទៀតពេលដែលពួកគាត់មានឧបករណ៍ទឹកស្អាត និងអនាម័យពួកគាត់ត្រូវប្រាប់បង ដូច្នេះបងអាចចុះពិនិត្យការតម្លើងនៅផ្ទះពួកគាត់។

| | |
|---|---|
| | ដើម្បីប្រាកដថាត្រឹមត្រូវ និងជូនសាប៊ូដុំឥតគិតថ្លៃចំនួន២ទៅពួកគាត់។<br>សូមសរសេរឈ្មោះរបស់បង និងលេខទូរស័ព្ទក្នុងខិត្តប័ណ្ណផង។<br><br>លោក...........................................................................<br><br>ទូរស័ព្ទទៅលេខនេះ<br><br>លេខទូរស័ព្ទ....................................................................<br><br>បាទ/ចាសប៉ុណ្ណឹង។<br>● បងៗទទួលបានអស់ហើយមែនទេ?<br>● តើបងៗនៅមានសំណួរអ្វីទេ?<br>ប្រជាពលរដ្ឋអាចនៅត្រូវការជំនួយពីបងមុនពេលដែលពួកគាត់សម្រេចចិត្តតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យដូច្នេះសូមជួយពួកគាត់ផង។<br>ពួកគាត់ស្តាប់បងៗហើយស្តាប់តាមការណែនាំរបស់បងដែលជាអាជ្ញាធរ។ |

## សកម្មភាពទី៩៖ ចែកខិត្តប័ណ្ណ និងស្លាកសាប៊ូ(៣ នាទី)

| ធ្វើ | និយាយ |
|---|---|
| ប្រាប់អ្នកចូលរួមពីរបៀបប្រើខិត្តប័ណ្ណ<br><br>ស្លាកនិងប្រគល់សាប៊ូពេលចុះជួបតាមផ្ទះ | ខ្ញុំដឹងថាវាងាយស្រួលណាស់សម្រាប់បងៗក្នុងការតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យនេះហើយបងៗនឹងជួយគាំទ្របងប្អូនអ្នកភូមិរបស់បងបានយ៉ាងល្អលើការងារនេះ។<br>**ខិត្តប័ណ្ណ៖**<br>សម្រាប់ការងារនេះយើងនឹងជូនខិត្តប័ណ្ណទាំងនេះទៅបង។ ដូច្នេះបងអាចយកតាមខ្លួនទុកចែកជូនគ្រួសារគោលដៅពេលបងចុះតាមផ្ទះដើម្បីជ្រើសរើសគ្រួសារគោលដៅដែលមិនទាន់មានឧបករណ៍ទឹកស្អាតនិងអនាម័យហើយមួយវិញទៀតបងនឹងតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យនៅផ្ទះដូច្នេះបងត្រូវមានខិត្តប័ណ្ណនៅផ្ទះផងដែរ។ បងអាចយកខិត្តប័ណ្ណដាក់តាំងបង្ហាញ និងជូនអ្នកមកមើលឧបករណ៍ទឹកស្អាត និងអនាម័យនៅផ្ទះរបស់បង។<br>**សាប៊ូ៖**<br>ដូចដែលបងបាន ដឹងពីខាងដើមហើយថាតួនាទីមួយរបស់បង គឺជូនសាប៊ូទៅអ្នកដែលបានតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យបានត្រឹមត្រូវដូច្នេះយើងស្នើបងស្លាកសាប៊ូទាំងនោះដែលវាមានភាពងាយស្រួលសម្រាប់បងពេលត្រូវប្រគល់សាប៊ូជូនពួកគាត់ពេលចុះពិនិត្យការតម្លើងតាមផ្ទះ។ បងត្រូវប្រគល់សាប៊ូចំនួន២ចំពោះអ្នកដែលបានតម្លើងបានត្រឹមត្រូវ។ យើងមានដាក់ព័ត៌មាននេះក្នុងខិត្តប័ណ្ណហើយក៏នឹងប្រាប់ប្រជាពលរដ្ឋពីការទទួលបានសាប៊ូនេះផងដែរដើម្បីជាការលើកទឹកចិត្តពួកគាត់ឱ្យមានឧបករណ៍ទឹកស្អាត និងអនាម័យប្រើនៅផ្ទះ។ |



## សកម្មភាពទី១០៖ ការចុះដល់ផ្ទះ(៥ នាទី)

| ធ្វើ | និយាយ |
|---|---|
| ប្រាប់ពួកគេពីគោលបំណងនៃការចុះជួប ដល់ផ្ទះ<br><br>បញ្ជីត្រួតពិនិត្យ | នេះជាការងារសំខាន់មួយរបស់បងហើយក៏ជាផ្នែកចុងក្រោយផងដែរនៃដំណើរការទាំងមូល។ បងនឹងទទួលបានការប្រាប់ដំណឹងអាចតាមរយៈទូរស័ព្ទ ឬផ្ទាល់មាត់ព្រោះបងនៅក្នុងភូមិស្រាប់ ដើម្បីប្រាប់អំពីការតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យ ឬស្នើសុំសាប៊ូឥតគិតថ្លៃដូច្នេះបងត្រូវរៀបចំការចុះពិនិត្យដល់ផ្ទះ។ គោលបំណងនៃការចុះពិនិត្យដល់ផ្ទះ គឺដើម្បីប្រាកដថាពួកគាត់បានបិទស្ទិកគ័រត្រឹមត្រូវ និងបានដាក់ត្រូវកន្លែងដែលបានកំណត់។ យើងមានបញ្ជីត្រួតពិនិត្យសម្រាប់បងពិនិត្យការងារនេះ។<br>1. តើស្ទិកគ័រ «មុនពេល» បិទនៅលើធុងលាងសម្អាតដៃដែរឬទេ?<br>2. តើការតម្លើងត្រឹមត្រូវដែរឬទេ?<br>- ក្បាលរ៉ូប៊ីណេ<br>- គម្រប<br>- ស្ទិកគ័រ<br>- កន្ទន់ត្រងទឹកកខ្វក់<br>3. តើធុងលាងសម្អាតដៃ «មុនពេល» ដាក់នៅផ្ទះបាយ/កន្លែងហូបបាយដែរឬទេ?<br>4. តើស្ទិកគ័រ «ក្រោយពេល» បិទនៅលើធុងលាងសម្អាតដៃដែរឬទេ?<br>5. តើការតម្លើងត្រឹមត្រូវដែរឬទេ?<br>- ក្បាលរ៉ូប៊ីណេ<br>- គម្របធុង<br>- ស្ទិកគ័រ<br>- កន្ទន់ត្រងទឹកកខ្វក់<br>6. តើធុងលាងសម្អាតដៃ «ក្រោយពេល» ដាក់នៅក្បែរបង្គន់ដែរឬទេ?<br>7. តើធុង/ដប មាននិមិត្តសញ្ញាសុវត្ថិភាព PETE 1 ដែរឬទេ?<br>8. តើស្ទិកគ័រ «ដាំឬចម្រោះនិងរក្សាទឹកទុកដោយសុវត្ថិភាព»បិទលើធុងសម្រាប់ដាក់ទឹកហូបដែរឬទេ?<br>9. តើពួកគេប្រើធុងទឹកតែមួយមែនទេពេលនេះ?<br>10. តើស្ទិកគ័រ«ទឹកនេះមិនមែនសម្រាប់ហូប»បិទលើទុយោទឹក/ពាង ទឹកដែរឬទេ? |

| សកម្មភាពទី១១៖ ប្រគល់សាប៊ូ និងប្រមូលលេខទូរស័ព្ទ(២ នាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| ជូនសាប៊ូ<br><br>កត់លេខទូរស័ព្ទ | ថ្លែងអំណរគុណទៅកាន់ប្រជាពលរដ្ឋរបស់បងសម្រាប់ការតាំងចិត្តទទួលយកនូវឥរិយាបថទឹកស្អាតនិងអនាម័យនេះ។ សូមលើកទឹកចិត្តពួកគាត់ឱ្យបន្តអនុវត្តឥរិយាបថទឹកស្អាត និងអនាម័យនេះដើម្បីប្រាកដថាពួកគាត់នឹងមិនមានជំងឺរាក និងតែងតែមានសុខភាពល្អ។<br>**ទម្រង់ប្រមូលទិន្នន័យ**<br>យើងនឹងជូនទម្រង់ប្រមូលព័ត៌មាននេះទៅបងដើម្បីសរសេរឈ្មោះ និងលេខទូរស័ព្ទអ្នកដែលបានតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យបានត្រឹមត្រូវ។<br>- ឈ្មោះ<br>- លេខទូរស័ព្ទ<br>ជូនសាប៊ូ<br>បន្ទាប់មកប្រគល់ទម្រង់ប្រមូលទិន្នន័យនេះមកIPCសូមអរគុណ |

| សកម្មភាពទី១២៖ បញ្ចប់(៧ នាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| សង្ខេបពីការងាររបស់ពួកគាត់ | មុនពេលយើងបញ្ចប់វគ្គនេះ ខ្ញុំសូមសង្ខេបពីការទទួលខុសត្រូវរបស់បងៗក្នុងសកម្មភាពនៃការផ្លាស់ប្តូរឥរិយាបថសង្គមផ្នែកទឹកស្អាតនិងអនាម័យដូចតទៅ៖<br>• ចុះជ្រើសរើសគ្រួសារគោលដៅ(មិនមានឧបករណ៍ទឹកស្អាតនិងអនាម័យ) និងប្រមូលលេខទូរស័ព្ទរបស់មេគ្រួសារ និងផ្ញើមកក្រុមការងារយើងខ្ញុំ<br>• រៀបចំ និងចាក់ឧបករណ៍បំពងសម្លេងនៅក្រៅផ្ទះរបស់បងៗ<br>• ដាក់តាំង/ចែកខិត្តប័ណ្ណ<br>• តម្លើង និងដាក់បង្ហាញឧបករណ៍ទឹកស្អាតនិងអនាម័យក្រៅផ្ទះដើម្បីឱ្យគេមើលឃើញ<br>• ស្តុកសាប៊ូ<br>• ចុះពិនិត្យតាមផ្ទះអ្នកដែលបានតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យ<br>¤ ត្រួតពិនិត្យការតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យថាត្រឹមត្រូវ<br>¤ ជូនសាប៊ូដុំចំនួន២ឥតគិតថ្លៃ និងស្ទិកគ័របិទទៅគ្រួសារដែលតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យបានត្រឹមត្រូវ<br>- ជូនតែសាប៊ូដុំចំនួន២ទេចំពោះគ្រួសារដែលបានទិញ និងតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យបានត្រឹមត្រូវ ព្រោះគាត់បានទទួលស្ទិកគ័រពីអ្នកលក់រួចហើយ<br>¤ កត់ឈ្មោះ និងលេខទូរស័ព្ទគ្រួសារដែលបានតម្លើង ឬជូនសាប៊ូនោះ<br>ខ្ញុំសង្ឃឹមថាបង នឹងចាត់ចែងពេលវេលាដើម្បីជួយប្រជាពលរដ្ឋរបស់បងឱ្យមាន |



| | |
|---|---|
| | សុខភាពល្អ។ ខ្ញុំគិតថាការងារទាំងនេះនឹងមិនប៉ះពាល់ដល់ការងារស្នូលរបស់បងៗទេ។<br>• មែនទេ បងៗ? |
| សារផ្តាំផ្ញើ | សូមរំលឹកប្រជាពលរដ្ឋថា «ដៃកខ្វក់និងទឹកកខ្វក់អាចបណ្តាលឱ្យកើតជំងឺរាក» ដូច្នេះសូមលាងសម្អាតដៃ នឹងសាប៊ូជានិច្ចដើម្បីធានាថាដៃស្អាតហើយសូមហូបតែទឹកដែលបានដាំ ឬចម្រោះនិងរក្សាទុកឱ្យមានសុវត្ថិភាពតែប៉ុណ្ណោះដើម្បីមានសុខភាពល្អ។ ផ្ទះមួយឧបករណ៍ទឹកស្អាត និងអនាម័យមួយកំប្លេ!<br>សូមបន្តអនុវត្តនិងណែនាំឱ្យប្រជាពលរដ្ឋរបស់បងឱ្យតែងតែ៖<br>• លាងសម្អាតដៃ នឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង៥<br>¤ មុនពេលធ្វើម្ហូប<br>¤ មុនពេលបញ្ចុកក្មេង<br>¤ មុនពេលបរិភោគ<br>¤ បន្ទាប់ពីលាងសម្អាតគូទទារក<br>¤ បន្ទាប់ពីបន្ទោបង់<br>• ហូបទឹកដែលបានដាំ ឬចម្រោះនិងរក្សាទុកឱ្យមានសុវត្ថិភាព<br>អស្ចារ្យណាស់ត្រូវប្រាកដថាបងអនុវត្តឥរិយាបថទាំងនេះ ដើម្បីឱ្យខ្លួនឯង និងគ្រួសាររបស់បងមានសុខភាពល្អ។ |
| សំណួរ/យោបល់ត្រលប់ | • តើបងៗមានយោបល់/សំណួរ/មតិអ្វីទេ?<br>• តើបងៗមានទំនុកចិត្តនឹងធ្វើការងារនេះទេ? |
| ប្រគល់ឧបករណ៍ទឹកស្អាតនិងអនាម័យ និងសម្ភារផ្សេងៗ | សូមទទួលយកឧបករណ៍ទឹកស្អាតនិងអនាម័យរបស់បងនិងសម្ភារផ្សេងៗទៀតដែលបានរៀបចំជាស្រេចហើយ។<br>បងដឹងពីរបៀបតម្លើងវាហើយហើយខ្ញុំគិតថាបងនឹងដាក់វាត្រូវកន្លែង។ |
| សូមអរគុណសម្រាប់ការចូលរួម | សូមអរគុណជាអនេកសម្រាប់ការចូលរួមនិងការតាំងចិត្ត។ |

## ការណែនាំលេខ២៖ ភ្នាក់ងារអប់រំ IPC ទូរស័ព្ទតាមដានការទទួលសារសម្លេងតាមទូរស័ព្ទ

| រយៈពេល | ក្រុមគោលដៅ | គោលបំណង |
|---|---|---|
| ៣ នាទី | - គ្រួសារដែលបានស្តាប់សារសម្លេងទូរស័ព្ទយ៉ាងហោចណាស់ចាប់ពី ៦៦%ឡើង<br>- អ្នកសម្របសម្រួល៖ ភ្នាក់ងារអប់រំ IPC | • ធ្វើការកត់ត្រាទិន្នន័យដើមគ្រា<br>• ចង់ដឹងពីការយល់អំពីសារ និងការចងចាំ<br>• ណែនាំពួកគាត់ឱ្យតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យដោយខ្លួនឯង ឬទិញវា |

**ការរៀបចំ**

- ត្រៀមមួយសប្តាហ៍មុនពេលទូរស័ព្ទតាមដាន
  - ¤ ជ្រើសរើសអ្នកដែលបានស្តាប់សារសម្លេងចាប់ពី៦៦%ឡើង
  - ¤ លេខទូរស័ព្ទ
- ពេលវេលាសម្ភាសន៍
  - ¤ ត្រៀមទម្រង់ប្រមូលព័ត៌មាន

**ឧបករណ៍/សម្ភារ**

- បញ្ជីឈ្មោះអ្នកទទួលសារសម្លេងទូរស័ព្ទ និងអ្នកដែលបានស្តាប់សារសម្លេងលើសពី៦៦%
- ទម្រង់ប្រមូលព័ត៌មាន
- ទូរស័ព្ទ (មានទឹកលុយសម្រាប់ទូរស័ព្ទ)

**ជំហាន៖**

១. សកម្មភាពទី១៖ ការស្វាគមន៍(១៥ វិនាទី)

២. សកម្មភាពទី២៖ ការសម្ភាសន៍(២ នាទី ៤០វិនាទី)

៣. សកម្មភាពទី៣៖ បញ្ចប់ (៥ វិនាទី)

**ជំហានលម្អិត**

| សកម្មភាពទី១៖ ការស្វាគមន៍(១៥ វិនាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| កិច្ចស្វាគមន៍<br>ការណែនាំខ្លួន<br>បញ្ជាក់ឈ្មោះនិងលេខទូរស័ព្ទ | សួស្តី ខ្ញុំឈ្មោះ..........................................................................<br>ខ្ញុំទូរស័ព្ទពីអង្គការខេមរា។<br>• តើខ្ញុំអាចសុំពេលបងបន្តិចជជែកជាមួយបងបានទេ?<br>• តើបងឈ្មោះ..........................................................................?<br>• ហើយនេះជាលេខរបស់បងមែនទេ?<br>សូមអរគុណ |

| សកម្មភាពទី២៖ ការសម្ភាសន៍(២ នាទី ៤០ វិនាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| សួរប្រសិនបើគាត់បានទទួលសារសម្លេងទូរស័ព្ទ | ខ្ញុំចង់សួរបងពីរបីសំណួរខ្លីៗ។<br>• តើបងបានទទួលសារសម្លេងតាមទូរស័ព្ទនិយាយពីសារអប់រំនិងឧបករណ៍ទឹកស្អាត និងអនាម័យទេ?<br>• តើបងទទួលសារសម្លេងនោះបានប៉ុន្មានដងដែរ?<br>• តើបងបានស្តាប់សារសម្លេងទាំងនោះទេ?<br>¤ ហេតុអ្វី?<br>• តើបងអាចប្រាប់ខ្ញុំបានទេគេនិយាយពីអ្វីដែរ?<br>(ចំណុចសំខាន់ៗសម្រាប់វាស់ការយល់របស់គាត់) |



| | |
|---|---|
| សួរគាត់ប្រសិនបើគាត់បានស្តាប់សារសម្លេងទូរស័ព្ទនោះ<br><br>ពិនិត្យមើលប្រសិនបើគាត់យល់ពីសារសម្លេងនោះ | ¤ លាងដៃរបស់អ្នក នឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង៥<br>¤ ដាំឬចម្រោះទឹកហូបនិងរក្សាទុកឱ្យមានសុវត្ថិភាព<br>¤ តម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យដោយខ្លួនឯង ឬទិញពីអ្នកលក់គ្រឿងប្លាស្ទិចដែលនៅជិតបំផុត<br>• តើបងដឹងទេថាតើឧបករណ៍ទឹកស្អាតនិងអនាម័យគឺជាអ្វីទៅ?<br>• តើបងធ្លាប់ឃើញឧបករណ៍ហ្នឹងនៅផ្ទះមេភូមិដែរឬទេ?<br>¤ ឧបករណ៍ទឹកស្អាត និងអនាម័យគឺជាឧបករណ៍សាមញ្ញដែលបងអាចតម្លើងខ្លួនឯងបានឬទិញពីអ្នកលក់ក្នុងតំបន់ដែលបងរស់នៅមានដូចជាក្បាលរ៉ូប៊ីណេ ធុងទឹក២០លីត្រ និងស្ទិកគ័រដែលបងជួយឱ្យបងមានកន្លែងលាងសម្អាតដៃបានដោយខ្លួនឯង និងធុងច្រកទឹកដែលមានសុវត្ថិភាពសម្រាប់ហូបផងដែរ។<br>¤ ប្រសិនបើបងតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យរបស់បង បងនឹងទទួលបានសាប៊ូដុំ២ដោយឥតគិតថ្លៃ<br>• តើបងដឹងថាហេតុអ្វីបានជាវាចាំបាច់ត្រូវលាងសម្អាតដៃរបស់បងនឹងសាប៊ូ និងហូបទឹកដែលបានដាំឬចម្រោះ និងរក្សាទុកឱ្យមានសុវត្ថិភាពដែរឬទេ?<br>¤ កាត់បន្ថយជំងឺដូចជារាកជាដើម |

| សកម្មភាពទី៣៖ បញ្ចប់(៥ វិនាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| អរគុណសម្រាប់ពេលវេលារបស់ពួកគាត់ | • តើបងមានសំណួរអ្វីទេ?<br>សូមអរគុណបងមែនទែនសម្រាប់ពេលវេលាអនុញ្ញាតឱ្យខ្ញុំជួប។<br>សូមសំណាងល្អនិងសុខភាពល្អបង! |

## ការណែនាំលេខ៣៖ មេភូមិចុះពិនិត្យដល់ផ្ទះ

| រយៈពេល | ក្រុមគោលដៅ | គោលបំណង |
|---|---|---|
| ១៥នាទី | មេគ្រួសារ<br>(គ្រួសារដែលបានតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យ) | • រៀបចំការចុះជួបដល់ផ្ទះដើម្បីពិនិត្យថាការតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យ ថាពិតជាត្រឹមត្រូវ ហើយបើមិនត្រឹមត្រូវត្រូវជួយពួកគាត់ធ្វើ និងដាក់ឱ្យត្រូវវិញ<br>• ជូនសាប៊ូដុំដោយឥតគិតថ្លៃទៅគ្រួសារដែលបានតម្លើង<br>• រំលឹក និងលើកទឹកចិត្តឱ្យគ្រួសារអនុវត្តឥរិយាបថទឹកស្អាតនិងអនាម័យទាំង២ (លាងសម្អាតដៃនឹងសាប៊ូ និងហូបទឹកសុវត្ថិភាព) |

**ការរៀបចំ**

- បញ្ជាក់អ្នកចូលរួមអំពីការចុះជួបដល់ផ្ទះ

**ឧបករណ៍/សម្ភារ**

- ទម្រង់ត្រួតពិនិត្យ
- ទម្រង់ប្រមូលទិន្នន័យ
- សាប៊ូ និងថង់សំណាញ់

**ជំហាន៖**

១. សកម្មភាពទី១៖ ការស្វាគមន៍(១ នាទី)
២. សកម្មភាពទី២៖ ត្រួតពិនិត្យការតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យ(១២ នាទី)
៣. សកម្មភាពទី៣៖ ជូនសាប៊ូដុំឥតគិតថ្លៃ(១ នាទី)
៤. សកម្មភាពទី៤៖ បញ្ចប់(១ នាទី)

**ជំហានលម្អិត**

**សកម្មភាពទី១៖ ការស្វាគមន៍(២ នាទី)**

| ធ្វើ | និយាយ |
|---|---|
| ស្វាគមន៍ចំពោះម្ចាស់ផ្ទះ<br>(ប្តី និងប្រពន្ធ)<br><br>សួរសំណួរខ្លះដើម្បីមានការចូលរួមពីពួកគាត់ | សួស្តី!<br>• តើសុខសប្បាយទេ?<br>• តើថ្ងៃនេះទំនេរនៅផ្ទះមែនទេ?<br>អរគុណហើយដែលបានអញ្ជើញខ្ញុំឱ្យមកលេងនិងមើលការតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យ។<br><br>បាទ ខ្ញុំមកលេងផង និងមកមើលការតម្លើងឧបករណ៍ផង។<br>• តើប្អូនមានអារម្មណ៍យ៉ាងណាបន្ទាប់ពី បានតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យរួចហើយ?<br>• តើខ្ញុំអាចទៅមើលការតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យរបស់ប្អូនបានទេ? |

**សកម្មភាពទី ២៖ ត្រួតពិនិត្យការតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យ(១២ នាទី)**

| ធ្វើ | និយាយ |
|---|---|
| ប្រើទម្រង់បញ្ជីត្រួតពិនិត្យដើម្បីកត់ត្រា | តោះទៅមើលការតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យរបស់ប្អូន<br>• តើប្អូនតម្លើងឧបករណ៍ដាក់នៅកន្លែងណាខ្លះ? |



| | |
|---|---|
| | • តើឥឡូវប្អូនមានឧបករណ៍ទឹកស្អាត និងអនាម័យប៉ុន្មានហើយ?<br>ខ្ញុំចង់មើលស្ទិកគ័របិទឱ្យជិតបន្តិច។ (គូសរង្វង់ ឬធីកតាមចំណុចនីមួយៗ)<br>1. តើស្ទិកគ័រ«មុនពេល» បិទនៅលើធុងលាងសម្អាតដៃដែរឬទេ?<br>2. តើការតម្លើងត្រឹមត្រូវដែរឬទេ?<br>- ក្បាលរ៉ូប៊ីណេ<br>- គម្រប<br>- ស្ទិកគ័រ<br>- កន្ទន់ត្រងទឹកកខ្វក់<br>3. តើធុងលាងសម្អាតដៃ «មុនពេល»ដាក់នៅផ្ទះបាយ/កន្លែងហូបបាយដែរឬទេ?<br>4. តើស្ទិកគ័រ «ក្រោយពេល»បិទនៅលើធុងលាងសម្អាតដៃដែរឬទេ?<br>5. តើការតម្លើងត្រឹមត្រូវដែរឬទេ?<br>- ក្បាលរ៉ូប៊ីណេ<br>- គម្របធុង<br>- ស្ទិកគ័រ<br>- កន្ទន់ត្រងទឹកកខ្វក់<br>6. តើធុងលាងសម្អាតដៃ «ក្រោយពេល» ដាក់នៅក្បែរបង្គន់ដែរឬទេ?<br>7. តើធុង/ដប មាននិម្មិតសញ្ញាសុវត្ថិភាព PETE 1 ដែរឬទេ?<br>8. តើស្ទិកគ័រ «ដាំឬចម្រោះនិងរក្សាទឹកទុកដោយសុវត្ថិភាព» បិទលើធុងទឹកសម្រាប់ហូបដែរឬទេ?<br>9. តើពួកគេប្រើធុងទឹកតែមួយមែនទេ?<br>10. តើស្ទិកគ័រ «ទឹកនេះមិនមែនសម្រាប់ហូប» បិទលើទុយោទឹក/ពាងទឹកដែរឬទេ? |

**សកម្មភាពទី៣៖ ជូនសាប៊ូដុំឥតគិតថ្លៃ(១ នាទី)**

| ធ្វើ | និយាយ |
|---|---|
| ជូនសាប៊ូដុំចំនួន២ឥតគិតថ្លៃទៅម្ចាស់ផ្ទះ | សូមអរគុណសម្រាប់ការតាំងចិត្តក្នុងការទទួលយកនូវឥរិយាបថទឹកស្អាត និងអនាម័យនេះ។ ខ្ញុំពិតជាពេញចិត្តចំពោះសកម្មភាពចូលរួមរបស់ប្អូនចំពោះទង្វើដើម្បីសុខភាពល្អនេះ។<br>សូមបន្តអនុវត្តឥរិយាបថលាងសម្អាតដៃនឹងសាប៊ូ និងហូបទឹកសុវត្ថិភាពដើម្បីធានាប្អូន និងគ្រួសារនឹងមិនមានជំងឺរាកហើយតែងតែមានសុខភាពល្អជានិច្ច។<br>នេះសាប៊ូរបស់ប្អូន!<br>ដូចបានសន្យា ប្អូនបានតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យ និងតម្លើងវាដូច្នេះខ្ញុំសូមជូនសាប៊ូដុំទាំងនេះទៅប្អូន។ សូមអរគុណ |

| សកម្មភាពទី៤៖ បញ្ចប់(១ នាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| សូមអរគុណចំពោះឆន្ទៈក្នុងការផ្លាស់ប្តូរឥរិយាបថដើម្បីសុខភាពល្អ | សូមរំលឹកថា«ដៃកខ្វក់និងទឹកកខ្វក់អាចបណ្តាលឱ្យកើតជំងឺរាក» ដូច្នេះសូមលាងសម្អាតដៃនឹងសាប៊ូជានិច្ចដើម្បីធានាថាដៃស្អាត ហើយសូមហូបតែទឹកដែលបានដាំឬចម្រោះនិងរក្សាទុកឱ្យមានសុវត្ថិភាពតែប៉ុណ្ណោះដើម្បីមានសុខភាពល្អ។ ផ្ទះមួយឧបករណ៍ទឹកស្អាតនិងអនាម័យមួយកំប្លេ!<br>សូមបន្តអនុវត្តនិងតែងតែ<br>● លាងសម្អាតដៃនឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង៥<br>¤ មុនពេលធ្វើម្ហូប<br>¤ មុនពេលបញ្ចុកក្មេង<br>¤ មុនពេលបរិភោគ<br>¤ បន្ទាប់ពីលាងសម្អាតគូទទារក<br>¤ បន្ទាប់ពីបន្ទោបង់<br>● ហូបទឹកដែលបានដាំឬចម្រោះ និងរក្សាទុកឱ្យមានសុវត្ថិភាព<br>អស្ចារ្យណាស់ត្រូវប្រាកដថាប្អូនអនុវត្តឥរិយាបថទាំងនេះដើម្បីឱ្យខ្លួនឯងនិងគ្រួសាររបស់មានសុខភាពល្អ។<br>សូមអរគុណ ជម្រាបលា! |

**សម្គាល់៖ ភ្នាក់ងារអប់រំ IPC នឹងទំនាក់ទំនង និងប្រមូលទិន្នន័យនៃការចុះជួបតាមផ្ទះនេះ។**

## ការណែនាំលេខ៤៖ វគ្គបណ្តុះបណ្តាលអ្នកលក់គ្រឿងប្លាស្ទិច និងសហគ្រាសតូច និងមធ្យម ផ្នែកទឹកស្អាត និងអនាម័យ

| រយៈពេល | ក្រុមគោលដៅ | គោលបំណង |
|---|---|---|
| ៥០នាទី | - ម្នាក់ទល់ម្នាក់ជាមួយអ្នកលក់គ្រឿងប្លាស្ទិច<br>- អ្នកសម្របសម្រួលសហគមន៍៖ ភ្នាក់ងារអប់រំ IPC | ● អាជីវករលក់គ្រឿងប្លាស្ទិចយល់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការលក់ឧបករណ៍ទឹកស្អាត និងអនាម័យ<br>● កន្លែងស្តុកឧបករណ៍ទឹកស្អាត និងអនាម័យត្រូវបានប្រជាពលរដ្ឋកត់ចំណាំស្គាល់តាមរយៈស្លាកសញ្ញាអាវយឺត និងការចាក់ឧបករណ៍បំពងសម្លេងនៅកន្លែងអ្នកលក់<br>● អាជីវការលក់គ្រឿងប្លាស្ទិចចេះពីរបៀបនិយាយលក់ឧបករណ៍ទឹកស្អាត និងអនាម័យទៅអតិថិជនកាន់តែប្រសើរ |



**ការរៀបចំ**

● មុនពេលវគ្គចាប់ផ្តើម

¤ ដាក់កម្មវិធីមុនមួយសប្តាហ៍

¤ ណាត់ជួបអាជីវករលក់គ្រឿងប្លាស្ទិចដែលនឹងជួបមួយទល់មួយនៅហាងរបស់គាត់ ឬទីតាំងសមរម្យដើម្បីពិភាក្សា

**ឧបករណ៍/សម្ភារ**

● ក្រដាសព័ត៌មានអំពីគម្រោង PHB

● ក្រដាសព័ត៌មានអំពីកម្មវិធីទឹកស្អាត និងអនាម័យ WASH (ប្រសិនបើមាន)

● បញ្ជីអាជីវករលក់គ្រឿងប្លាស្ទិចក្នុងតំបន់

● កញ្ចប់ឧបករណ៍ទឹកស្អាត និងអនាម័យ (ធុងទឹកមានគម្រប ធុង(ដប)ដាក់ទឹកហូប ក្បាលរ៉ូប៊ីណេ កន្ទន់ សាប៊ូ)

● ព័ត៌មានទំនាក់ទំនងអ្នកផ្គត់ផ្គង់ (សម្រាប់អាជីវករកម្មង់ទិញឧបករណ៍ទឹកស្អាត និងអនាម័យ)

● ស្ទិកគ័រ (មុនពេលក្រោយពេលទឹកហូបទឹកនេះមិនមែនសម្រាប់ហូប)

● អាវយឺត

● សារសម្លេងស្តីពីទឹកស្អាត និងអនាម័យ សម្រាប់ចាក់ឧបករណ៍បំពងសម្លេង

● ស្លាកសញ្ញា

● ទម្រង់ប្រមូលព័ត៌មាន

**ជំហាន៖**

សកម្មភាពទី១៖ ការស្វាគមន៍ (៥ នាទី)

សកម្មភាពទី២៖ ការណែនាំពីគម្រោង PHB(២ នាទី)

សកម្មភាពទី៣៖ ការណែនាំពីសកម្មភាពនៃការផ្លាស់ប្តូរឥរិយាបថផ្នែកទឹកស្អាត និងអនាម័យ (៥ នាទី)

សកម្មភាពទី៤៖ តួនាទី និងការទទួលខុសត្រូវរបស់អ្នកលក់គ្រឿងប្លាស្ទិច (៥ នាទី)

សកម្មភាពទី៥៖ ពិនិត្យឧបករណ៍ និងសម្ភារផ្សេងៗ (១នាទី)

សកម្មភាពទី៦៖ ឧបករណ៍/សម្ភារផ្សព្វផ្សាយ (៥ នាទី)

សកម្មភាពទី៧៖ សម្ភារសម្រាប់ចែក (៧ នាទី)

សកម្មភាពទី៨៖ កម្មង់ និងស្តុកឧបករណ៍ទឹកស្អាត និងអនាម័យ (១០ នាទី)

សកម្មភាពទី៩៖ របៀបនិយាយទៅកាន់អតិថិជន (៦ នាទី) - សូមមើលការណែនាំទី៥

សកម្មភាពទី១០៖ ពិនិត្យមើលទម្រង់ប្រមូលព័ត៌មាន (១ នាទី)

សកម្មភាពទី១១៖ សង្ខេបការងារ (២ នាទី)

សកម្មភាពទី១២៖ ប្រគល់ឧបករណ៍/សម្ភារ (៥០ វិនាទី)

សកម្មភាពទី១៣៖ បញ្ចប់ (១០ វិនាទី)

**ជំហានលម្អិត៖**

| សកម្មភាពទី១៖ ការស្វាគមន៍(៥ នាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| អង្គុយទាំងអស់តែត្រូវរក្សាគម្លាតណែនាំខ្លួនអ្នកនិងអរគុណគាត់ | សួស្តីបង ខ្ញុំឈ្មោះ _____________ មកពីអង្គការខេមរា។សូមអរគុណសម្រាប់ការចំណាយពេលវេលាពិភាក្សាជាមួយខ្ញុំ។ |

| | |
|---|---|
| សម្រាប់<br>ការចំណាយពេលវេលាជួបពិភាក្សា | |
| ចង់ដឹងពីការរំពឹងទុករបស់គាត់ | ខ្ញុំ នឹងបង្ហាញបងអំពីការងាររបស់គម្រោងហើយថាតើវាទាក់ទងយ៉ាងណាទៅនឹងអាជីវកម្មរបស់បង។<br>ខ្ញុំគិតបងបានទទួលព័ត៌មានខ្លះៗហើយអំពីគម្រោងសុខភាពនេះ មែនទេ?<br>• តើបងមានការរំពឹងទុកដូចម្តេចដែរពីការប្រជុំនេះ? |
| ណែនាំឱ្យស្គាល់គ្នាទៅវិញទៅមក | វាពិតជាល្អណាស់!<br>យើងអាចណែនាំស្គាល់គ្នាបន្តិចបន្ទាប់មកខ្ញុំនឹងជម្រាបបងថាហេតុអ្វីបានជាយើងមកទីនេះ។យើងសុំស្គាល់បងបន្តិចសិន។<br>• តើបងអាចប្រាប់ឈ្មោះបានទេ?<br>• តើបងប្រកបរបរ/ធ្វើការអ្វីដែរ?<br>• តើបងចាប់យកមុខរបរនេះរយៈពេលប៉ុន្មានហើយ? |
| ប្រាប់ពីគោលបំណងនៃកិច្ចប្រជុំ | មូលហេតុដែលមានការប្រជុំនេះពីព្រោះយើងចង់បានបងចូលរួមជាផ្នែកមួយនៃការងារទឹកស្អាតនិងអនាម័យនៅក្នុងសហគមន៍។ យើងដឹងថាបងប្រកបរបរលក់គ្រឿងប្លាស្ទិច ហើយបងចង់បង្កើនការលក់ក្នុងគោលដៅមួយដើម្បីទទួលបានប្រាក់ចំណេញច្រើនត្រឹមត្រូវទេ?<br><br>បងលក់ឧបករណ៍ទឹកស្អាត និងអនាម័យហើយគម្រោងយើងធ្វើលើការងារអប់រំផ្នែកទឹកស្អាតនិងអនាម័យដើម្បីធ្វើការផ្លាស់ប្តូរឥរិយាបថប្រជាពលរដ្ឋឱ្យអនុវត្តនូវឥរិយាបថ ឬសកម្មភាពដែលត្រឹមត្រូវដូច្នេះគឺវាល្អខ្លាំងណាស់ក្នុងការសហការគ្នាដើម្បីជួយប្រជាពលរដ្ឋសហគមន៍ឱ្យទទួលបានឧបករណ៍ទឹកស្អាតនិងអនាម័យប្រើប្រាស់ និងអនុវត្តនូវឥរិយាបថអនាម័យដែលនឹងនាំឱ្យពួកគាត់មានសុខភាពល្អ។<br><br>ដូចដែលបងបានលើកពីខាងដើមចឹង៖<br>• តើបងមានលក់ធុងទឹកមានគម្របក្បាលរ៉ូប៊ីណេ កន្ទន់ និងធុងដាក់ទឹកហូប (ដបធំ) ២០លីត្រ ដែរឬទេ?<br>បើមិនមានមិនអីទេយើង នឹងជជែកបន្ថែមពីរឿងនេះ។ |

| សកម្មភាពទី២៖ ការណែនាំពីគម្រោង PHB(២ នាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| ចាប់ផ្តើមនិយាយពីគម្រោង | ខ្ញុំចង់បង្ហាញបងពីគម្រោងរបស់យើងដែលមានឈ្មោះថា គម្រោង «លើកកម្ពស់ឥរិយាបថប្រកបដោយសុខុមាលភាព-PHB»។<br>• តើស្តាប់ទៅគិតថាម៉េចដែរបង? |



| | |
|---|---|
| ការណែនាំអំពីគម្រោង PHB តាមរយៈស្លាយឬវីដេអូខ្លីអំពីទិដ្ឋភាពទូទៅនៃគម្រោង<br><br>បង្ហាញក្រដាសណែនាំសង្ខេបអំពីគម្រោងនិងបញ្ជាក់លើចំណុចសំខាន់ៗ(ប្រសិនបើអាច)<br><br>• គោលបំណង<br>• ផ្នែកសុខភាពសំខាន់ៗ<br>• តំបន់គោលដៅ<br>• សហប្រតិបត្តិការ និងអ្នកអនុវត្តកម្មវិធី | ខ្ញុំចង់ជម្រាបបងជ្រាបថា គម្រោងលើកកម្ពស់ឥរិយាបថប្រកបដោយសុខុមាលភាព (PHB) គឺមានរយៈពេល៥ឆ្នាំដែលទទួលបានមូលនិធិពីទីភ្នាក់ងារសហរដ្ឋអាមេរិចសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ដែលដឹកនាំអនុវត្តដោយអង្គការអន្តរជាតិបំរើសុខភាពប្រជាជន (PSI)។<br>គម្រោង PHB គឺមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវឥរិយាបថសុខភាពក្នុងចំណោមប្រជាជនកម្ពុជា និងគាំទ្រនូវគោលដៅរបស់ USAID កម្ពុជាដើម្បីធានាថាប្រជាជនកម្ពុជាស្វែងរក និងទទួលបាននូវការថែទាំសុខភាពប្រកបដោយគុណភាពដោយកាត់បន្ថយនូវការចំណាយផ្សេងៗ តាមរយៈប្រព័ន្ធដែលមាននិរន្តរភាព។<br><br>សម្រាប់នៅខេត្តត្បូងឃ្មុំនេះ គឺសកម្មភាពនៃកម្មវិធី នឹងត្រូវអនុវត្តគម្រោងដោយអង្គការខេមរា។<br><br>គម្រោង PHB គឺមានកិច្ចសហប្រតិបត្តិការសំខាន់ៗ ដូចជាក្រសួងអភិវឌ្ឍន៍ជនបទ (MRD) និងមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព (NCHP) នៃក្រសួងសុខាភិបាល។ |
| ទុកពេលឱ្យអ្នកចូលរួមសួរសំណួរ | • តើបងប្អូនមានសំណួរអ្វីដែរឬទេ?<br>ល្អខ្ញុំ នឹងបង្ហាញបន្តពីសកម្មភាពនៃការផ្លាស់ប្តូរឥរិយាបថសង្គមផ្នែកទឹកស្អាត និងអនាម័យ។ |

| សកម្មភាពទី៣៖ ការណែនាំពីសកម្មភាពនៃការផ្លាស់ប្តូរឥរិយាបថផ្នែកទឹកស្អាត និងអនាម័យ (៥ នាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| ទាញការចូលរួម<br>អនុញ្ញាតអ្នកចូលរួមធ្វើការចែករំលែកខ្លីអំពីបទពិសោធន៍ទាក់ទងនឹងការងារទឹកស្អាត និងអនាម័យ<br>អរគុណគាត់សម្រាប់ការចែករំលែក | • តើបងធ្លាប់ចូលរួមឬពាក់ព័ន្ធសកម្មភាពការងារទាក់ទង នឹងទឹកស្អាត និងអនាម័យពីមុនមកទេ? (វគ្គបណ្តុះបណ្តាល ការរកស៊ី)<br>ល្អណាស់សូមអរគុណសម្រាប់ការចែករំលែករបស់បង។<br><br>បងរស់នៅក្នុងសហគមន៍នេះដូច្នេះបងស្គាល់ប្រជាពលរដ្ឋ និងអតិថិជនរបស់បងច្បាស់ណាស់។ ខ្ញុំគិតថាបង នឹងក្លាយជាអ្នកលក់ដ៏ឆ្នើមក្នុងសហគមន៍។ |
| ធ្វើឱ្យមានការចូលរួមពីគាត់អំពីទឹកស្អាត និងអនាម័យ | ឥឡូវខ្ញុំចង់ដកស្រង់ចំណុចសំខាន់ៗមួយចំនួនដែលទាក់ទង នឹងការងារទឹកស្អាត និងអនាម័យ។ នៅពេលយើងនិយាយពីទឹកស្អាត និងអនាម័យ។<br>• តើពាក្យថាទឹកស្អាត និងអនាម័យមានន័យដូចម្តេចទៅ?<br>សូមអរគុណសម្រាប់ការចែករំលែករបស់បង។ |

| | |
|---|---|
| | បាទ/ចាសគឺមានចំណុចពសំខាន់ដែលត្រូវផ្ដោតទៅលើគឺការលាងសម្អាតដៃនឹងសាប៊ូ ហូបទឹកសុវត្ថិភាព និងការប្រើបង្គន់អនាម័យ។<br><br>ប៉ុន្តែសម្រាប់ការងាររបស់យើងគឺយើងផ្ដោតលើឥរិយាបថសំខាន់ៗតែ២ទេគឺ៖<br>1. លាងសម្អាតដៃ នឹងសាប៊ូ<br>2. ការដាំឬចម្រោះទឹកហូបនិងរក្សាទុកឱ្យមានសុវត្ថិភាព<br><br>ចំពោះការលាងសម្អាតដៃនឹងសាប៊ូគឺមានឥរិយាបថសំខាន់ៗចំនួន៥ ដើម្បីធ្វើការផ្លាស់ប្ដូរដូចជាការលាងដៃ នឹងសាប៊ូ៖<br>1. មុនពេលធ្វើម្ហូប ឬប៉ះពាល់ម្ហូបអាហារ<br>2. មុនពេលបញ្ចុកក្មេង<br>3. មុនពេលបរិភោគ<br>4. បន្ទាប់លាងសម្អាតគូទទារក<br>5. បន្ទាប់ពីបន្ទោបង់<br>ខ្ញុំគិតថាបងទទួលបានអ្វីៗទាំងអស់ដែលយើងកំពុងធ្វើ និងមូលហេតុដែលយើងមកថ្ងៃនេះ។ ដូចបានជម្រាបពីខាងលើអីចឹងបងគឺ ជាបុគ្គលដែលសំខាន់ បំផុតដែលស្គាល់ប្រជាពលរដ្ឋសហគមន៍របស់បងឥរិយាបថរបស់ប្រជាពលរដ្ឋនិងតម្រូវការរបស់ពួកគាត់ ហេតុនេះបងគឺជាធនធានដ៏មានតម្លៃដែលមិនអាចខ្វះបានសម្រាប់សកម្មភាព នៃការផ្លាស់ប្ដូរឥរិយាបថសង្គមផ្នែកទឹកស្អាត និងអនាម័យនេះ ដូច្នេះហើយយើងពិតជាត្រូវការបងចូលរួម ក្នុងអន្តរាគមន៍កែប្រែឥរិយាបថសហគមន៍ដើម្បីគ្រប់គ្នាមានសុខភាពល្អ។ |
| ណែនាំពីឥរិយាបថសំខាន់ៗ | យើងចង់ឱ្យគ្រួសារនៅជនបទតម្លើង ឬទិញឧបរកណ៍ទឹកស្អាត និងអនាម័យ ដូច្នេះពួកគាត់អាចលាងសម្អាតដៃរបស់ពួកគាត់នឹងសាប៊ូមុនពេលធ្វើម្ហូប មុនពេលបញ្ចុកក្មេង មុនពេលបរិភោគក្រោយពេលលាងសម្អាតគូទទារក និងក្រោយពេលបន្ទោបង់ និងដាំឬចម្រោះទឹកហូបនិងរក្សាទុកឱ្យមានសុវត្ថិភាព។ ដូច្នេះពួកគាត់ និងគ្រួសាររបស់ពួកគាត់មានសុខភាពល្អ!<br><br>យើងចង់ឱ្យបងលក់ឧបករណ៍ទាំងនេះ ពីព្រោះយើងចង់ឱ្យបងក្លាយជាអ្នកលក់ឆ្នើមផ្នែកទឹកស្អាត និងអនាម័យក្នុងសហគមន៍របស់បង។ |
| ក្លាយជាអ្នកលក់ឆ្នើមផ្នែកទឹកស្អាត និង អនាម័យ | ភាពជាអ្នកលក់ឆ្នើមផ្នែកទឹកស្អាត និងអនាម័យបងមិនគ្រាន់តែជាបុគ្គលសង្គម (មនុស្សដែលទទួលបានការគោរព និងឱ្យតម្លៃពីមនុស្សក្នុងសង្គម) ប៉ុណ្ណោះទេ តែបង នឹងទទួលបានអតិថិជនច្រើនដូច្នេះបង នឹងទទួលបានប្រាក់ចំណេញច្រើន អាស្រ័យនឹងចំនួនឧបករណ៍ទឹកស្អាត និងអនាម័យដែលបងបានលក់។ វាមានន័យថាប្រជាពលរដ្ឋស្គាល់បង និងហាងរបស់បងថាជាកន្លែងស្ដុកឧបករណ៍ទឹក |



| | |
|---|---|
| | ស្អាត និងអនាម័យហើយពេលណាគិតទាក់ទងនឹងឧបករណ៍/សម្ភារឬរបស់របរទាក់ទងនឹងទឹកស្អាតនិងអនាម័យគេនឹងគិតដល់បង និងមករកបងហើយ។ ភាពជាបុគ្គលឆ្នើមមួយរូបវា នឹងកសាងកេរ្តិ៍ឈ្មោះរបស់បងនៅក្នុងសហគមន៍របស់បង និងក្នុងសង្គម។ បងមិនគ្រាន់តែទទួលបានផលប្រយោជន៍ពីការលក់ដូររបស់បងទេតែបង នឹងទទួលបានរូបភាពមួយល្អក្នុងសង្គមដូចអ្វីដែលបងបានកំពុងជួយសហគមន៍របស់បងឱ្យមានសុខភាពល្អតាមរយៈការគាំទ្រ និងផ្ដល់ពួកគាត់នូវសារអប់រំ និងឧបករណ៍ទឹកស្អាត និងអនាម័យក្នុងការផ្លាស់ប្ដូរពួកគាត់ឱ្យអនុវត្តឥរិយាបថផ្នែកទឹកស្អាត និងអនាម័យឱ្យបានត្រឹមត្រូវតាមរយៈការទទួលបានពេញលេញនូវឧបករណ៍ទឹកស្អាត និងអនាម័យសម្រាប់ប្រើប្រាស់។<br>• តើបងពិតជាចង់ឱ្យមុខរបររបស់បងរីកចម្រើនមែនទេ?<br>• តើបងពិតជាចង់ជួយប្រជាពលរដ្ឋក្នុងសហគមន៍ឱ្យមានសុខភាពល្អមែនទេ? |

| សកម្មភាពទី៤៖ តួនាទី និងការទទួលខុសត្រូវរបស់អ្នកលក់គ្រឿងប្លាស្ទិច(៧ នាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| ប្រាប់គាត់ពីតួនាទីរបស់គាត់<br><br>ទុកពេលឱ្យគាត់សួរបញ្ជាក់ និងសំណួរផ្សេងៗ | បងបានឆ្លើយថា «ជួយ» សម្រាប់សហគមន៍របស់បង។<br>ល្អណាស់ ខ្ញុំចង់ជម្រាបបងពីការងារសំខាន់ៗដែលបងអាចចាត់ចែង និងទទួលខុសត្រូវ។<br><br>តួនាទីរបស់បងគឺ៖<br>• តម្លើងស្លាកសញ្ញានេះនៅមុខហាង<br>• ពាក់អាវយឺត<br>• ចាក់សារសម្លេងស្ដីពីទឹកស្អាត និងអនាម័យដែលបានថតជូនបងសម្រាប់ចាក់ក្នុងឧបករណ៍បំពងសម្លេងរបស់បង<br>• តម្លើងឧបករណ៍ទឹកស្អាត និងអនាម័យដើម្បីដាក់បង្ហាញនៅហាង<br>• កម្មង់និងស្ដុកឧបករណ៍ទឹកស្អាត និងអនាម័យ<br>• ស្ដុកស្ទិកគ័រ និងខិត្តប័ណ្ណ<br>• និយាយទាក់ទាញអតិថិជនឱ្យទិញឧបករណ៍ទឹកស្អាតនិងអនាម័យ<br>• លក់ឧបករណ៍ទឹកស្អាត និងអនាម័យ<br>• ជូនស្ទិកគ័រទៅអ្នកដែលទិញឧបករណ៍ទឹកស្អាតនិងអនាម័យ<br>• កត់ត្រាចំនួនឧបករណ៍ទឹកស្អាតនិងអនាម័យដែលបានលក់<br>កុំបារម្ភខ្ញុំ នឹងពន្យល់ការងារមួយម្ដងៗហើយបងអាចពិភាក្សា និងបញ្ជាក់បានលើការងារនេះ។<br>• តើបងគិតយ៉ាងម៉េចដែរបង? |

## សកម្មភាពទី៥៖ ពិនិត្យឧបករណ៍ និងសម្ភារផ្សេងៗ(១ នាទី)

| ធ្វើ | និយាយ |
|---|---|
| ដាក់បង្ហាញឧបករណ៍<br>និងសម្ភារទាំងអស់ | ទាំងនេះជាឧបករណ៍/សម្ភារដែល នឹងត្រូវប្រើប្រាស់ក្នុងអន្តរាគមន៍ទឹកស្អាត និងអនាម័យនេះ។ យើងនឹងប្រគល់ជូនបងរបស់ទាំងនេះដែលមានគោលបំណងផ្សេងៗគ្នាដែលខ្ញុំនឹងលម្អិតបន្ទាប់នេះ។<br>• ស្លាកសញ្ញា<br>• អាវយឺត<br>• ស្ទិកគ័រ<br>• ខិត្តប័ណ្ណ<br>• ប្លង់និយាយលក់ទៅកាន់អតិថិជន<br>• ទម្រង់ប្រមូលព័ត៌មាននៃការលក់ |

## សកម្មភាពទី៦៖ ឧបករណ៍/សម្ភារផ្សព្វផ្សាយ(៥ នាទី)

| ធ្វើ | និយាយ |
|---|---|
| លើកបង្ហាញឧបករណ៍មួយម្តងៗ ដើម្បីបង្ហាញពីសម្ភារផ្សព្វផ្សាយ ឧបករណ៍ទឹកស្អាត និងអនាម័យ នៅហាងរបស់គាត់<br><br>ស្លាកសញ្ញា<br><br>អាវយឺត<br><br>សារសម្លេងសម្រាប់ចាក់នឹង ឧបករណ៍បំពងសម្លេង | មានឧបករណ៍ជាច្រើនដែលជួយផ្សព្វផ្សាយផលិតផលឧបករណ៍ទឹកស្អាត និងអនាម័យនៅហាងរបស់បង។<br><br>• **ស្លាកសញ្ញា**<br>នេះជាស្លាកសញ្ញាដែលបងត្រូវតម្លើងនៅមុខហាងរបស់បងដូច្នេះអ្នកទិញអាចមើលឃើញ និងដឹងថាកន្លែងរបស់បងមានលក់ឧបករណ៍ទឹកស្អាត និងអនាម័យ។គេសរសេរថា«ឧបករណ៍ទឹកស្អាត និងអនាម័យមានលក់នៅទីនេះ» និង «មើលឃើញស្អាតមិនប្រាកដថាមានសុវត្ថិភាពទេ»។ ស្លាកសញ្ញានេះអាចប្រាប់ព្រមទាំងទាក់ទាញ អតិថិជនមកទិញឧបករណ៍ទឹកស្អាតនិងអនាម័យពីហាងរបស់បង និងសម្ភារផ្សេងៗទៀតផងដែរ។<br><br>• **អាវយឺត**<br>បាទ/ចាស អាវយឺតនេះមើលទៅស្អាតណាស់ហើយមើលទៅត្រូវរាងបងតែម្តង ។នេះជាសម្ភារផ្សព្វផ្សាយផលិតផលទឹកស្អាត និងអនាម័យមួយដែរ។ បងត្រូវពាក់អាវយឺតនេះដែលជាអ្នកតំណាងផ្នែកទឹកស្អាតនិងអនាម័យមួយរូបនៅផ្សារនេះ ។បងដឹងហើយថាបងជាអ្នកលក់ឧបករណ៍ទឹកស្អាតនិងអនាម័យដូច្នេះអ្នកដើរផ្សារនឹងមើលមកបងហើយពេលគេត្រូវការគេនឹងមករកបងតែម្តង។ អាវយឺតនឹងអាចជួយផ្សព្វផ្សាយហាងរបស់បងនិងជួយជំរុញ |
| | ការទិញផងដែរ។ នៅលើអាវគេសរសេរថា «មើលឃើញស្អាតមិនប្រាកដថាមានសុវត្ថិភាពទេ» និងខាងក្រោមនេះគេសរសេរថា «លាងសម្អាតដៃរបស់អ្នកនៅពេលវេលាសំខាន់ៗទាំង៥»ដោយមានរូបសញ្ញាយ៉ាងស្អាតច្បាស់ៗខាងក្រោមនេះទៀតនិង «ដាំឬចម្រោះទឹកហូប និងរក្សាទុកឱ្យមានសុវត្ថិភាព»។ សូមពាក់អាវយឺតនេះព្រោះបងបានតាំងចិត្តថាជួយប្រជាពលរដ្ឋរបស់បង។<br><br>• **សារម្លេង**<br>យើងបានថតជាសារសម្លេងសម្រាប់បងចាក់។<br>- តើខ្ញុំអាចផ្ញើសារសម្លេងនេះ ទៅបងតាមវិធីណា?<br>- តើខ្ញុំអាចផ្ញើសារសម្លេងតាម Telegram បងឬផ្ញើផ្ទាល់ទៅទូរស័ព្ទរបស់បងតែម្តង?<br><br>• **ខិត្តប័ណ្ណ**<br>នេះជាខិត្តប័ណ្ណសម្រាប់ចែក។ វាជួយអតិថិជនរបស់បងពិចារណាទិញឧបករណ៍ទឹកស្អាត និងអនាម័យ។ វាផ្តល់ព័ត៌មានស្តីពីការអនុវត្តឥរិយាបថទឹកស្អាត និងអនាម័យ ប្រសិនបើពួកគាត់ចង់មានសុខភាពល្អ។ ហើយវាបានជួយផ្សព្វផ្សាយជំរុញអតិថិជនឱ្យទិញឧបករណ៍ទឹកស្អាត និងអនាម័យ ហើយតាមរយៈការទិញពួកគាត់នឹងទទួលបានសាប៊ូដុំចំនួន២ដោយឥតគិតថ្លៃហើយវានឹងជួយបង្កើនការលក់របស់បង។ បងឃើញត្រង់នេះហើយទាក់ទងទៅ មេភូមិដើម្បីទទួលបានសាប៊ូដុំឥតគិតថ្លៃ។ ហើយនៅផ្នែកខាងក្រោយ នេះគេបង្ហាញពីរបៀបតម្លើងឧបករណ៍លាងសម្អាតដៃដោយខ្លួនឯងទៀតផង ដែលអាចជួយឱ្យពួកគាត់តម្លើងដោយខ្លួនឯងបាន។ វាពិតជាមានប្រយោជន៍ណាស់។ បងអាចប្រើខិត្តប័ណ្ណេនះ ដើម្បីពន្យល់ទៅអតិថិជនរបស់បង ប្រសិនបើពួកគាត់ត្រូវការជំនួយបន្ថែម។<br><br>• **ឧបករណ៍ទឹកស្អាត និងអនាម័យមួយឈុត**<br>យើងក៏នឹងជូនបងនូវឧបករណ៍ទឹកស្អាត និងអនាម័យនេះមួយឈុតសម្រាប់បងតម្លើង និងដាក់តាំងបង្ហាញអតិថិជនរបស់បងនៅមុខហាងផងដែរ។ |

## សកម្មភាពទី៧៖ សម្ភារសម្រាប់ចែក(៧ នាទី)

| ធ្វើ | និយាយ |
|---|---|
| | ទាំងនេះជាស្ទិកគ័រស្តីពីទឹកស្អាតនិងអនាម័យ។ យើងនឹងទុកស្ទិកគ័រទាំងនេះក្នុងចំនួនកំណត់មួយនៅនឹងបង។ នេះជាការងារមួយរបស់បងគឺទុកនិងចែកស្ទិកគ័រ អនាម័យ។ បងត្រូវប្រគល់ស្ទិកគ័រ៥នេះទៅអតិថិជនរបស់បងពេលគេ |

<table>
<tr>
<td>បង្ហាញស្ទិកគ័រទាំងអស់<br><br>ពន្យល់មួយម្តងៗ</td>
<td>ទិញឧបករណ៍ទឹកស្អាត និងអនាម័យ។<br>
• លាងសម្អាតដៃរបស់អ្នក នឹងសាប៊ូ «មុនពេល» ចំនួន១<br>
• លាងសម្អាតដៃរបស់អ្នក នឹងសាប៊ូ «ក្រោយពេល» ចំនួន១<br>
• ដាំទឹកឬចម្រោះទឹកហូប និងរក្សាទុកឱ្យមានសុវត្ថិភាពចំនួន២<br>
• ទឹកនេះមិនមែនសម្រាប់ហូបទេចំនួន១<br>
សូមពិនិត្យមើលស្ទិកគ័រទាំងនេះទាំងអស់គ្នា។ ពេលក្រោយបងអាចពន្យល់និងណែនាំអតិថិជនរបស់បងបាន។ ព្រមទាំងគំរូក្រឹតសម្រាប់ចោះរន្ធធ្វើធុងលាងសម្អាតដៃនេះផងដែរ។<br><br>
ស្ទិកគ័រលាងសម្អាតដៃរបស់អ្នកនឹងសាប៊ូ<br>
អក្សរធំៗផ្នែកខាងលើគេសរសេរថា«មើលឃើញស្អាត មិនប្រាកដថាមានសុវត្ថិភាពទេ»និង«លាងសម្អាតដៃរបស់អ្នកនឹងសាប៊ូ» ដើម្បីរំលឹកពីដៃកខ្វក់ និងណែនាំឱ្យលាងសម្អាតដៃ នឹងសាប៊ូសាប៊ូដើម្បីប្រាកដថាដៃហ្នឹងស្អាតមានសុវត្ថិភាព។ ស្ទិកគ័រទាំងនេះ នឹងត្រូវបិទនៅលើធុងលាងសម្អាតដៃ។ ស្ទិកគ័រនេះមានពីរគឺ «លាងសម្អាតដៃរបស់អ្នកនឹងសាប៊ូ»គឺមួយ«មុនពេល» និងមួយទៀត«ក្រោយពេល»មែនទេ?<br>
មុនពេល<br>
1. ធ្វើម្ហូប<br>
2. បញ្ចុកក្មេង<br>
3. បរិភោគ<br>
ក្រោយពេល<br>
4. លាងសម្អាតគូទទារក<br>
5. បន្ទោបង់<br>
ហើយនៅផ្នែកខាងក្រោមខាងស្តាំនេះគេសរសេរថា «ទឹកនេះមិនមែនសម្រាប់ហូបទេ»។ គេរំលឹកយើងថាទឹកមិនទាន់បន្សុទ្ធហ្នឹងគឺមិនមែនសម្រាប់ហូបទេ ប៉ុន្តែគេប្រើសម្រាប់លាងសម្អាតដៃ និងរបស់របរផ្សេងៗ។<br><br>
ស្ទិកគ័រដាំឬចម្រោះទឹកហូប និងរក្សាទុកឱ្យមានសុវត្ថិភាព<br>
ស្ទិកគ័រនេះបិទនៅលើធុងឬដបធំសម្រាប់ច្រកទឹកហូប។ សារសំខាន់ទីនេះគេសរសេរថា«មើលឃើញស្អាតមិនប្រាកដថាមានសុវត្ថិភាពទេ»ហើយនៅខាងក្រោមនេះគេបញ្ជាក់ថា «សូមដាំឬចម្រោះទឹកហូប និងរក្សាទុកឱ្យមានសុវត្ថិភាពតែប៉ុណ្ណោះ»។ វាជួយរំលឹកបងនូវឥរិយាបថ ឬទង្វើដើម្បីមានសុខភាពល្អ។ ក្រាហ្វិកនេះបង្ហាញពីដំណើរការ ឬជំហានដើម្បីទឹកសុវត្ថិភាពសម្រាប់ហូប។<br>
1. លាងសម្អាតធុងទឹក នឹងសាប៊ូ<br>
2. ដាំឬចម្រោះទឹក<br>
3. ទុកឱ្យត្រជាក់ចាក់ចូលក្នុងធុងគ្របវាហើយហូបទឹកនោះ<br>
4. នៅពេលដែលទឹកក្នុងធុងជិតអស់ធ្វើតាមដំណើរដដែលសម្រាប់ធុងទឹកទីពីរ។</td>
</tr>
</table>



<table>
<tr>
<td></td>
<td>នៅផ្នែកខាងលើខាងស្តាំគេសរសេរថា «ទឹកនេះសម្រាប់ហូប»។ គេបញ្ជាក់ថាទឹកនេះគឺមានសុវត្ថិភាពសម្រាប់ហូបហើយ។ វាជាការល្អដែលត្រូវមានធុងដាក់ទឹកចំនួន២ដើម្បីធានាថា នឹងមិនអស់ទឹកសុវត្ថិភាពហូបដោយពួកគាត់អាចដូរ ឬឆ្លាស់ធុងដាក់ទឹកដើម្បីលាងសម្អាតវា។<br><br>
ទឹកនេះមិនមែនសម្រាប់ហូបទេ<br>
នេះជាស្ទិកគ័រដាច់ដោយឡែកមួយទៀត«ទឹកនេះមិនមែនសម្រាប់ហូបទេ» សម្រាប់បិទលើពាងទឹក ឬបំពង់ទុយោទឹកដើម្បីប្រាប់រំលឹកប្រជាពលរដ្ឋថាទឹកហ្នឹងមិនទាន់បន្សុទ្ធ (ដាំ ឬចម្រោះ) ហើយវាមិនទាន់មានសុវត្ថិភាពទេ។<br>
• តើបងមានសំណួរអ្វីទាក់ទង នឹងស្ទិកគ័រទាំងនេះទេ?<br><br>
គំរូក្រឹត<br>
គំរូក្រឹតនេះ គឺសម្រាប់ជំនួយក្នុងការចោះរន្ធធុងលាងសម្អាតដៃឱ្យមានត្រឹមត្រូវ និងស្អាតផងដែរ។ យើងត្រូវកាត់ប្រឡោះតាមរង្វង់នេះសិន ហើយចោះរន្ធឱ្យប៉ុននឹងទំហំនេះ ព្រោះវាប៉ុនគ្នានឹងទំហំនៃក្បាលរ៉ូប៊ីណេដែរ។ ហើយក្រឹតតូចនេះសម្រាប់ចោះគម្រប ដើម្បីឱ្យមានខ្យល់ចេញចូល។<br><br>
តម្លើងឧបករណ៍ទឹកស្អាត និងអនាម័យ:<br>
សម្រាប់ឧបករណ៍ទឹកស្អាតនិងអនាម័យនេះបងអាចតម្លើងវាបានយ៉ាងងាយស្រួលដោយបងអាចមើលតាមការណែនាំក្នុងខិត្តប័ណ្ណពីជំហានទី១ ដល់ ទី១០ នេះទៅជាការស្រេចទៅហើយ។ លើសពីនេះទៀតដូចបង្ហាញខាងលើគឺត្រូវបិទស្ទិកគ័រហើយយកទៅដាក់ឱ្យបានត្រឹមត្រូវនៅកន្លែងដែលត្រូវប្រើប្រាស់ដូចជាធុងលាងសម្អាតដៃ នៅផ្ទះបាយ/កន្លែងហូបបាយ និងមួយទៀតនៅក្រោបង្គន់ជាដើម។</td>
</tr>
</table>

<table>
<tr>
<th colspan="2">សកម្មភាពទី៨៖ កម្មង់ និងស្តុកឧបករណ៍ទឹកស្អាត និងអនាម័យ(១០ នាទី)</th>
</tr>
<tr>
<th>ធ្វើ</th>
<th>និយាយ</th>
</tr>
<tr>
<td>តម្លៃឧបករណ៍ទឹកស្អាត<br>និងអនាម័យ</td>
<td>នេះជាអ្វីដែលបងត្រូវធ្វើសម្រាប់មុខរបរអាជីវកម្មរបស់បង ប្រសិនបើបងត្រូវកម្មង់ឧបករណ៍ទឹកស្អាត និងអនាម័យចូលស្តុក។<br>
កញ្ចប់ឧបករណ៍ទឹកស្អាតនិងអនាម័យមានដូចជា៖<br>
• ធុងសម្រាប់ដាក់ទឹកហូបចំណុះ២០លីត្រ ចំនួន២ (ឬធុងដែលងាយស្រួលសម្អាតមានគម្រប និងក្បាលរ៉ូប៊ីណេ និងមាននិម្មិតសញ្ញាសុវត្ថិភាព PETE 1)</td>
</tr>
</table>

| | |
|---|---|
| | • ក្បាល់រ៉ូប៊ីណេ២ សម្រាប់ធ្វើឧបករណ៍លាងសម្អាតដៃ<br>• ស្ទិកគ័រចំនួន ៥<br>• គំរូក្រឹតចោះរន្ធចំនួន ១<br>កញ្ចប់ឧបករណ៍នេះគឺមានតម្លៃតិចជាង៤ដុល្លា សម្រាប់បងទិញចូលស្តុក។<br>• តើបងគិតថាតម្លៃនៃកញ្ចប់ឧបករណ៍នេះ ៥ដុល្លាយ៉ាងម៉េចដែរ?<br>បងគួរតែលក់ឧបករណ៍នេះក្នុងតម្លៃ ៤-៥ដុល្លា។ |
| ស្តុកឧបករណ៍ទឹកស្អាត និងអនាម័យ | អតិថិជនក៏អាចចង់ទិញធុងទឹកមានគម្របថ្មី និងកន្ទន់ពីបងដើម្បីដាក់នៅកន្លែងលាងសម្អាតដៃរបស់គាត់ផងដែរ។<br><br>បងត្រូវពិនិត្យចាត់ចែងស្តុករបស់បងដើម្បីធានាថាបងអាចផ្គត់ផ្គង់អ្វីដែលគេត្រូវការ។<br><br>យើងនឹងជូនស្ទិកគ័រដែលបានពិភាក្សាគ្នាមុននេះ និងគំរូក្រឹតចោះរន្ធទៅបងដោយឥតគិតថ្លៃសម្រាប់ទុកឱ្យអតិថិជនបងដែលទិញឧបករណ៍ទឹកស្អាតនិងអនាម័យ។នេះជាព័ត៌មានសម្រាប់ទំនាក់ទំនងអ្នកផ្គត់ផ្គង់គ្រឿងប្លាស្ទិចក្នុងករណីដែលបងត្រូវការកម្មង់៖......................................................... |
| ដាក់តាំងបង្ហាញឧបករណ៍ទឹកស្អាត និងអនាម័យ | បងក៏ត្រូវតម្លើងឧបករណ៍ទឹកស្អាត និងអនាម័យមួយឈុតដើម្បីដាក់តាំងបង្ហាញនៅមុខហាងរបស់បងដូច្នេះគេអាចមើលគំរូនេះបាន។<br>ហើយបងត្រូវដឹងពីរបៀបតម្លើងវា។ វាគឺងាយស្រួល មែនទេ? |

| សកម្មភាពទី៩៖ របៀបនិយាយទៅកាន់អតិថិជន(៦ នាទី) - សូមមើលការណែនាំទី៥ | |
|---|---|
| **សកម្មភាពទី១០៖ ពិនិត្យមើលទម្រង់ប្រមូលព័ត៌មាន(១ នាទី)** | |
| **ធ្វើ** | **និយាយ** |
| បង្ហាញទម្រង់កត់ត្រាការលក់ | អូខេ នេះជាទម្រង់ប្រមូលព័ត៌មាន។<br>វាជួយយើងថាមានអតិថិជនប៉ុន្មាននាក់បានទិញឧបករណ៍ទឹកស្អាតនិងអនាម័យ។សូមបងជួយបំពេញចំនួនឧបករណ៍ដែលបងបានលក់ចេញ។<br>• តើបងមានសំណួរពីទម្រង់នេះទេ? |

| សកម្មភាពទី១១៖ សង្ខេបការងារ(២ នាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| សង្ខេបការងាររបស់គាត់ | មុនពេលបិទបញ្ចប់ការពិភាក្សា និងចែករបស់របរទាំងនេះ។<br>ខ្ញុំសូមសង្ខេបការងារដែលបងត្រូវធ្វើមានដូចខាងក្រោម៖<br>• តម្លើងស្លាកសញ្ញានេះនៅមុខហាង<br>• ពាក់អាវយឺត<br>• ចាក់សារសម្លេងស្តីពីទឹកស្អាត និងអនាម័យដែលបានថតជូនបងសម្រាប់ចាក់ក្នុងឧបករណ៍បំពងសម្លេងរបស់បង<br>• តម្លើងឧបករណ៍ទឹកស្អាត និងអនាម័យដើម្បីដាក់បង្ហាញនៅមុខហាង<br>• កម្មង់ និងស្តុកឧបករណ៍ទឹកស្អាត និងអនាម័យ<br>• ស្តុកស្ទិកគ័រ និងខិត្តប័ណ្ណ<br>• និយាយទាក់ទាញអតិថិជនឱ្យទិញឧបករណ៍ទឹកស្អាត និងអនាម័យ<br>• លក់ឧបករណ៍ទឹកស្អាត និងអនាម័យ<br>• ជូនស្ទិកគ័រទៅអ្នកដែលបានទិញឧបករណ៍ទឹកស្អាត និងអនាម័យ<br>• កត់ត្រាចំនួនឧបករណ៍ទឹកស្អាត និងអនាម័យដែលបានលក់<br>ខ្ញុំគិតថាបងនឹងទទួលបានអតិថិជនច្រើន និងកសាងកត្តិយសសង្គមផងដែរ។<br>• តើបងមានសំណួរចំពោះអ្វីដែលបងត្រូវធ្វើដែរឬទេ? |

| សកម្មភាពទី១២៖ ប្រគល់ឧបករណ៍/សម្ភារ(៥០ វិនាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| ជូនឧបករណ៍ និងសម្ភារ | ទាំងនេះជាឧបករណ៍/សម្ភារសម្រាប់បង។<br>សូមតម្លើងស្លាកសញ្ញានេះ នៅមុនហាងរបស់បង។<br>• ស្លាកសញ្ញាចំនួន១<br>• អាវយឺតចំនួន១<br>• ប្លង់និយាយទៅអតិថិជនចំនួន១<br>• ទម្រង់កត់ត្រាចំនួនលក់ចំនួន១(កាលបរិច្ឆេទការលក់សម្ភារ ស្ទិកគ័របានប្រគល់)<br>• ស្ទិកគ័រចំនួន........ឈុត<br><br>**ស្ទិកគ័រមួយឈុតរួមមាន៖**<br>¤ លាងសម្អាតដៃរបស់អ្នកនឹងសាប៊ូមុនពេលចំនួន១<br>¤ លាងសម្អាតដៃនឹងសាប៊ូក្រោយពេលចំនួន១<br>¤ ដាំឬច្រោះទឹកហូប និងរក្សាទុកឱ្យមានសុវត្ថិភាពចំនួន២ |

| | |
|---|---|
| | ¤ ទឹកនេះមិនមែនសម្រាប់ហូបចំនួន១<br>¤ ខិត្តប័ណ្ណចំនួន១<br>¤ គំរូក្រឹតតូចលើគម្របចំនួន១<br>¤ គំរូក្រឹតលើធុងចំនួន១ |

| សកម្មភាពទី១៣៖ បញ្ចប់ (១០ វិនាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| អរគុណសម្រាប់ការសហការរបស់បង | សូមអរគុណបងសម្រាប់ពេលវេលាចូលរួមនិងការសហការលើការងារទឹកស្អាតនិងអនាម័យនេះ។<br><br>ប្រសិនបើបងមានសំណួរឬចង់បញ្ជាក់សូមទាក់ទងមកខ្ញុំ តាមរយៈលេខ .....<br><br>សូមជូនពរសំណាងល្អ! |

**សម្គាល់៖ អាជីវករត្រូវកត់ត្រាទិន្នន័យលក់ក្នុងទម្រង់នេះ។ IPC នឹងមកប្រមូលទម្រង់ទិន្នន័យនេះ។**

## ការណែនាំលេខ៥៖ របៀបលក់ឧបករណ៍ទឹកស្អាតនិងអនាម័យ

| រយៈពេល | ក្រុមគោលដៅ | គោលបំណង |
|---|---|---|
| ៦នាទី | - អ្នកនិយាយ៖ អាជីវលក់ គ្រឿងប្លាស្ទិច<br>- អតិថិជន៖ មេគ្រួសារ | • ជួយអ្នកលក់គ្រឿងប្លាស្ទិចនិយាយទាក់ទាញអតិថិជនឱ្យទិញឧបករណ៍ទឹកស្អាតនិងអនាម័យ<br>• ណែនាំពីរបៀបតម្លើងឧបករណ៍ទឹកស្អាតនិងអនាម័យដោយខ្លួនឯង<br>• ប្រាប់អតិថិជនដែលបានទិញឧបករណ៍ទាក់ទងមេភូមិចុះពិនិត្យដល់ផ្ទះពេលពួកគេតម្លើងឧបករណ៍អនាម័យរួចដើម្បីទទួលបានសាប៊ូឥតគិតថ្លៃ |

**ការរៀបចំ**

- ដាក់បង្ហាញឧបករណ៍ទឹកស្អាតនិងអនាម័យ
- ខិត្តប័ណ្ណតែងតែមានជានិច្ចនៅហាង



**ឧបករណ៍/សម្ភារ**

- កញ្ចប់ឧបករណ៍ទឹកស្អាត និងអនាម័យនិងសម្ភារសម្រាប់ដំឡើង
- ស្ទិកគ័រ
- ខិត្តប័ណ្ណ
- គំរូក្រឹតបោះវន្ត
- ទម្រង់ប្រមូលព័ត៌មាន
- ប្លង់សម្រាប់និយាយទៅកាន់អតិថិជន (បម្រុង)

**ជំហាន៖**

សកម្មភាពទី១៖ ស្វាយគមន៍ (៣០ វិនាទី)
សកម្មភាពទី២៖ របៀបលក់ទៅកាន់អតិថិជន (៥ នាទី)
សកម្មភាពទី៣៖ បញ្ចប់ (៣០ វិនាទី)

**ជំហានលម្អិត៖**

| សកម្មភាពទី១៖ ការស្វាគមន៍ (៣០ វិនាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| ស្វាគមន៍អតិថិជនរបស់អ្នក | សួស្តី! សូមស្វាគមន៍ការមកកាន់ហាងរបស់ខ្ញុំ។<br>ឧបករណ៍ទឹកស្អាតនិងអនាម័យគឺមានលក់នៅទីនេះ។<br>• តើបងត្រូវការអ្វីដែរ?<br><br>នៅទីនេះយើងមានលក់ឧបករណ៍ទឹកស្អាតនិងអនាម័យហើយនៅទីនេះវាមានឧបករណ៍/សម្ភារចាំបាច់ដែលអ្នកត្រូវការសម្រាប់ធ្វើធុងលាងសម្អាតដៃដោយខ្លួនឯង និងធុងសម្រាប់ដាក់ទឹកហូបដែលបានដាំ ឬចម្រោះរួចឱ្យមានសុវត្ថិភាព។ |

| សកម្មភាពទី២៖ របៀបលក់ទៅកាន់អតិថិជន (៥ នាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| និយាយទាក់ទាញអតិថិជន | ឧបករណ៍ទឹកស្អាត និងអនាម័យគឺវាល្អ និងជាវិធីងាយស្រួលមួយសម្រាប់ការពារខ្លួនអ្នក និងគ្រួសាររបស់អ្នកពីជំងឺរាក និងជំងឺដទៃទៀតដូចជាកូវីដជាដើម! |

| | |
|---|---|
| | ពីព្រោះមិនមែនមេរោគទាំងអស់អាចមើលឃើញទេ។ មើលឃើញស្អាតមិនប្រាកដថាមានសុវត្ថិភាពទេ!<br><br>បងអាចការពារខ្លួន និងគ្រួសារពីមេរោគទាំងឡាយដោយការលាងសម្អាតដៃនឹងសាប៊ូនៅពេលវេលាសំខាន់ៗទាំង៥ និងហូបតែទឹកដែលបានដាំ ឬចម្រោះនិងរក្សាទុកដោយសុវត្ថិភាពប៉ុណ្ណោះ។ មែនទេ?<br>គុណសម្បត្តិនៃការមានឧបករណ៍ទឹកស្អាតនិងអនាម័យទាំងនេះគឺ៖<br>• កន្លែងលាងសម្អាតដៃមានក្បាលរ៉ូប៊ីណេគឺវាងាយស្រួលប្រើប្រាស់ហើយស្អាតជាងការប្រើបោយទឹក<br>• ក្មេងៗក៏អាចលាងសម្អាតដៃដោយខ្លួនឯងបានផងដែរ<br>• មិនដែលអស់ទឹកហូប<br>• មានកន្លែងលាងសម្អាតដៃនិងធុងដាក់ទឹកហូបធំៗមានន័យថាអ្នកមានពេលវេលាច្រើនជាមួយគ្រួសារ<br>• ទទួលបានសាប៊ូដោយឥតគិតថ្លៃហើយ «ពិសេស» ស្ទិកគ័រដ៏ស្រស់ស្អាតសម្រាប់បិទរំលឹកពីការអនុវត្តឥរិយាបថទឹកស្អាត និងអនាម័យទៀតផង<br><br>កញ្ចប់ឧបករណ៍ទឹកស្អាតនិងអនាម័យគឺមានវាដូចជា៖<br>• ធុងសម្រាប់ដាក់ទឹកហូបមានចំណុះ២០លីត្រចំនួន២<br>• ក្បាលរ៉ូប៊ីណេសម្រាប់ធ្វើធុងលាងសម្អាតដៃចំនួន២<br>• ស្ទិកគ័រចំនួន៥<br>• គំរូក្រឹតសម្រាប់ស្វានរន្ធ១<br>• ខិត្តប័ណ្ណរបៀបតម្លើងឧបករណ៍ចំនួន១<br>វាមានតម្លៃ(៤-៥ដុល្លា)<br><br>នៅពេលបងទិញឧបករណ៍ទឹកស្អាតនិងអនាម័យថ្ងៃនេះបង នឹងទទួលបានសាប៊ូដុំចំនួន២ដោយឥតគិតថ្លៃពីមេភូមិរបស់បងសម្រាប់ប្រើនៅកន្លែងលាងសម្អាតដៃ។ វាមានដាក់បញ្ជាក់នៅលើខិត្តប័ណ្ណនេះស្រាប់។ នេះជាប្រូម៉ូសិន។<br>• តើបងឃើញទេ? នៅត្រង់នេះ!<br>បើបងត្រូវការធុងទឹកមានគម្របនិងកន្ទន់សម្រាប់ធ្វើកន្លែងលាងសម្អាតដៃ ខ្ញុំក៏មានលក់ដែរ ឬបងចង់បានឈុតលាងសម្អាតដៃដែលធ្វើស្រេចក៏មាន។<br><br>នេះជារបស់ដែលបងត្រូវការ។ បងអាចធ្វើវានៅផ្ទះដោយខ្លួនឯង។<br>• តើបងដឹងថាត្រូវធ្វើ ឬតម្លើងវាយ៉ាងម៉េចទេ?<br><br>បងអាចមើលតាមការណែនាំក្នុងខិត្តប័ណ្ណដែលបងទទួលបានពីមេភូមិ ឬបងអាចយកមួយពីទីនេះក៏បាន។<br>ខ្ញុំរីករាយនឹងណែនាំពីរបៀបធ្វើបើបងត្រូវការ។ (សូមណែនាំតាមជំហាននៃរបៀបដំឡើងធុងលាងសម្អាតដៃ ដែលរៀបរាប់ក្នុងខិតប័ណ្ណ)។ |



| សកម្មភាពទី៣៖ បញ្ចប់ (៣០ វិនាទី) | |
|---|---|
| **ធ្វើ** | **និយាយ** |
| បញ្ចប់ | សូមអរគុណជាខ្លាំងសម្រាប់ការមកហាងរបស់ខ្ញុំនិងជាវឧបករណ៍ទឹកស្អាតនិងអនាម័យទីនេះ។<br><br>សូមអនុវត្តការលាងសម្អាតដៃ និងហូបទឹកដែលបានដាំឬចម្រោះ និងរក្សាទុកឱ្យមានសុវត្ថិភាពដើម្បីធានាថាបង និងគ្រួសាររបស់បង នឹងមិនមានជំងឺរាក ឬមានជំងឺផ្សេងៗដូចជាជំងឺកូវីដ-១៩ជាដើមដោយសារការខ្វះអនាម័យ។<br><br>ហើយកុំភ្លេចទាក់ទងទៅមេភូមិរបស់បងដើម្បីយកសាប៊ូឥតគិតថ្លៃ។ (យើងផ្តល់ជូនសម្រាប់តែភូមិដែលស្ថិតនៅក្នុងតំបន់គោលដៅប៉ុណ្ណោះ)<br><br>សូមជូនពរបង និងគ្រួសារមានសុខភាពល្អ។ |

**ចំណាំ៖ អាជីវករត្រូវកត់ត្រាទិន្នន័យលក់ក្នុងទម្រង់នេះ។ IPC នឹងមកប្រមូលទម្រង់ទិន្នន័យនេះ។**

## ទំនាក់ទំនងព័ត៌មាន

**ប្រសិនបើមានសំណួរអំពីសៀវភៅណែនាំនេះរបៀបអនុវត្តអន្តរាគមន៍ ឬការប្រើប្រាស់ឧបករណ៍/សម្ភារ សូមទំនាក់ទំនង៖**

**ឈ្មោះ៖ ដឹប ស្រីពេជ្រ**
**តួនាទី៖ អ្នកសម្របសម្រួលជាន់ខ្ពស់**
អង្គការ៖ PSI
ទូរស័ព្ទ៖ 012 976 908
អ៊ីម៉េល៖ dsreypech@psi.org.kh